ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(២៧)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(27)

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Aug-2013, 15:35
CMS/CFO: Sann Rada

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម Judge Florence Ndepele Mwachande MUMBA
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣
**ភាសាដើម៖** ខ្មែរ/អង់គ្លេស/បារាំង
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

---

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅលើសំណើសុំដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

1. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួល "បណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំដោះលែងឱ្យនៅក្រៅឃុំជាបន្ទាន់ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" ដែលមេធាវីការពារក្តី ខៀវ សំផន ("មេធាវីការពារក្តី") បានដាក់កាលពីថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៣ ("បណ្តឹងសាទុក្ខ")[1]។

## I. ប្រវត្តិនីតិវិធី

2. បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានចេញនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ដែលបដិសេធសំណើមួយដែលបានដាក់ដោយមេធាវីការពារក្តីនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ដែលសុំដោះលែង ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់ដោយដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ("សេចក្តីសម្រេចដែលត្រូវបានជំទាស់" និង "ពាក្យសុំ")[2]។

### ក. សាវតា

3. ខៀវ សំផន ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ដោយដីការបស់សហចៅក្រមស៊ើបអង្កេត[3]។ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកា

---

[1] ឯកសារ E275/2/1។

[2] សេចក្តីសម្រេចលើសំណើសុំដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣, ឯកសារ E275/1; *សំណើសុំដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ,* ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ E275។

[3] *សូមមើល* ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧, ឯកសារ C26។ *សូមមើលផងដែរ* ដីកាដែលបដិសេធសំណើសុំដោះលែង, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៨, ឯកសារ C36/III; ដីកាសម្រេចពន្យារចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៨, ឯកសារ C26/4; សេចក្តីសម្រេចលើសំណើជាយថាហេតុរបស់លោក ខៀវ សំផន សុំដោះលែងឱ្យមានសេរីភាព, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៨, ឯកសារ C26/5/5; សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំខុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យារចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារ C26/5/26; ដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ C26/8; សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០, ឯកសារ C26/7/12។

ដំណោះស្រាយក្នុងសំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក ("សំណុំរឿង ០០២") ដែលចោទប្រកាន់ ខៀវ សំផន ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងការរំលោភក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[4]។ សហចៅក្រមស៊ើបអង្កេតបានបង្គាប់បន្ថែមថា ខៀវ សំផន ត្រូវស្ថិតក្នុងការឃុំខ្លួនបណ្ដោះអាសន្នរហូតដល់ថ្ងៃដែលត្រូវនាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[5]។ បន្ទាប់មក អង្គបុរេជំនុំជម្រះបានបញ្ជាក់គាំទ្រការបន្តការឃុំខ្លួន ខៀវ សំផន បណ្ដោះអាសន្នជាបន្តទៀត[6]។

4. នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំដោះលែង ខៀវ សំផន បណ្ដោះអាសន្ន[7]។ ក្នុងបណ្ដឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្ដល់សំអាងហេតុឲ្យបានគ្រប់គ្រាន់ដើម្បីបង្ហាញថា ខៀវ សំផន មានហានិភ័យដោយការរត់គេចខ្លួន និងបង្គាប់ឲ្យបន្តឃុំខ្លួន អនុលោមតាមវិធាន ៦៣(៣)(ខ)(៣) នៃវិធានផ្ទៃក្នុង[8]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា មូលដ្ឋានផ្លូវច្បាប់សម្រាប់ការឃុំខ្លួន ខៀវ សំផន បណ្ដោះអាសន្នតាមវិធាន ៦៣(៣)(ខ)(៣) នៃវិធានផ្ទៃក្នុង នៅតែមានសុពលភាព ដោយសារអង្គហេតុបង្ហាញពីហានិភ័យថា ជនជាប់ចោទអាចនឹងមិនចូលរួមការជំនុំជម្រះ[9]។

5. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ មេធាវីការពារក្ដីបានដាក់ពាក្យសុំ ដោយលើកឡើងថា ខៀវ សំផន មិនធ្លាប់ប៉ុនប៉ងលាក់ខ្លួនទេ ទោះបីជាគាត់ដឹងថា គាត់ប្រឈមនឹងការកាត់ទោសក៏ដោយ ហើយថាគាត់បានប្រគល់ខ្លួនដោយសុទ្ធចិត្តនៅពេលចាប់ខ្លួន[10]។ មេធាវីការពារក្ដីបានលើកឡើងបន្ថែមថា ខៀវ សំផន មិនអាចគេចខ្លួនបានទេ ដោយសារគាត់មានវ័យចាស់ជរា ភាពក្រីក្រ ពុំមានឯកសារសម្រាប់ធ្វើ

---

[4] ដីកាដំណោះស្រាយ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D427 ("ដីកាដំណោះស្រាយ")។

[5] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៦២២ ដល់ ១៦២៤។

[6] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១, ឯកសារ D427/4/15។

[7] សេចក្ដីសម្រេចលើសំណើសុំដោះលែងជាបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ E50 ("សេចក្ដីសម្រេចលើកទីមួយរបស់ អ.ជ.ស.ដ លើសំណើសុំដោះលែងជាបន្ទាន់")។

[8] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំជាបន្ទាន់, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E50/3/1/4 ("សេចក្ដីសម្រេចលើកទីមួយរបស់ អ.ជ.ត.ក លើសំណើសុំដោះលែងជាបន្ទាន់")។

[9] សេចក្ដីសម្រេចលើកទីមួយរបស់ អ.ជ.ស.ដ លើសំណើសុំដោះលែងជាបន្ទាន់, កថាខណ្ឌ ៥៤។

[10] សំណើសុំ, កថាខណ្ឌ ២៨។

ដំណើរ និងមានឆន្ទៈក្នុងការចាកចេញពីគ្រួសារគាត់ទេ[11]។ មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា មានការត្រួតពិនិត្យតាមផ្លូវតុលាការ អមជាមួយវិធានការត្រួតពិនិត្យតាមផ្លូវតុលាការមួយចំនួនរួមមាន៖ ការធានាពី ខៀវ សំផន ស្នាក់នៅអាសយដ្ឋានពិសេសណាមួយ, ប្រគល់អត្តសញ្ញាណប័ណ្ណជូន អ.វ.ត.ក, អនុញ្ញាតឱ្យអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យជាទៀងទាត់ និងមានវត្តមានពេលសវនាការ គឺគ្រប់គ្រាន់សម្រាប់បន្ធូរបន្ថយហានិភ័យនៃការរត់គេចខ្លួន[12]។

6. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចផ្ទាល់មាត់ ដោយចេញសំអាងហេតុជាលាយល័ក្ខអក្សរនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ដោយបំបែកសំណុំរឿង ០០២ ជាថ្មីជាសវនាការតូចៗ ("សេចក្តីសម្រេចលើកទីពីរ លើការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២") និងកំណត់វិសាលភាពនៃសវនាការលើកទីមួយ ដើម្បីកំណត់ចំនួនចោទបទ ("សំណុំរឿង ០០២/០១")[13] បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលទុកជាមោឃៈនូវសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ ដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង ("សេចក្តីសម្រេចលើកទីមួយ លើការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២" និង "សេចក្តីសម្រេចលើកទីមួយរបស់ អ.ជ.ត.ក លើសំណើសុំដោះលែងជាបន្ទាន់")[14]។

7. នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងទទួលយកជាភស្តុតាងជាអត្ថបទដកស្រង់មួយចំនួនពីសៀវភៅមួយក្បាលដែលនិពន្ធដោយអតីតសហចៅក្រមស៊ើបអង្កេតនៅ អ.វ.ត.ក គឺចៅក្រម Marcel LEMONDE និងសុំឱ្យពិចារណាទៅលើអត្ថបទដកស្រង់ទាំងនោះនៅពេលសម្រេចទៅលើពាក្យសុំ ("សំណើ")[15]។ នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីនានាថា ដោយសារពុំ

---

[11] សំណើសុំ, កថាខណ្ឌ ២៩។

[12] សំណើសុំ, កថាខណ្ឌ ៤៦ ដល់ ៦២។

[13] ប្រតិចារឹក, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ E1/176.1, ទំព័រ ១ ដល់ ៤; សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E284, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចលើកទីពីរ លើការបំបែកកិច្ចដំណើរការនីតិវិធី")។

[14] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ឯកសារ E163/5/1/13, ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[15] *សំណើលើកទី ១ សុំដាក់បញ្ចូលអត្ថបទដកស្រង់ចេញពីសៀវភៅលោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល,* ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣, ឯកសារ E280។

មានពេលវេលាគ្រប់គ្រាន់ពិចារណាទៅលើសំណើនោះ អង្គជំនុំជម្រះមិនពិចារណាលើបញ្ហានេះមុនពេលសម្រេចលើពាក្យសុំទេ ហើយថា សំណើនឹងត្រូវយកមកវិនិច្ឆ័យសម្រេចទៅតាមនីតិវិធីជាបទដ្ឋាន ដោយឱ្យភាគីមានឱកាសក្នុងការផ្តល់យោបល់លើបញ្ហានេះ[16]។ បន្ទាប់មក ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីនានាថា អង្គជំនុំជម្រះសាលាដំបូងសម្រេចបើកសវនាការលើសំណើសុំដោះលែងជាបន្ទាន់ដោយពុំពិចារណាទៅដល់ភស្តុតាងថ្មីដែលមេធាវីការពារក្តីបានស្នើ ហើយបានសន្និដ្ឋានថា សំណើសុំនេះមិនសំខាន់ទេ[17]។ នៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានដាក់សំណើទីពីរសុំដាក់អត្តបទដកស្រង់នានាពីសៀវភៅដែលនិពន្ធដោយចៅក្រម LEMONDE នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ("សំណើបន្ថែម")[18]។

8. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់ ដោយបដិសេធពាក្យសុំ និងបានបង្គាប់ឱ្យបន្តឃុំខ្លួន ខៀវ សំផន។

## ខ. បណ្តឹងសាទុក្ខ

9. នៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានប្តឹងសាទុក្ខ ដោយលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសជាច្រើនដែលនាំឱ្យសេចក្តីសម្រេចដែលត្រូវបានជំទាស់ពុំមានសុពលភាព[19]។ មេធាវីការពារក្តីអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានផ្តោតដោយមិនត្រឹមត្រូវចំពោះហានិភ័យនៃការរត់គេចខ្លួន និងការលំបាកក្នុងការរៀបចំចាត់ចែង និងមិនបានថ្លឹងថ្លែងឱ្យបានពេញលេញដល់ការធានាដែលបានផ្តល់ជូន និងលក្ខខណ្ឌនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលបានស្នើឡើង[20]។ ហេតុនេះ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលមោឃៈសេចក្តីសម្រេចដែលត្រូវបាន

[16] ប្រតិចារឹក, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣, ឯកសារ E1/180.1, ទំព័រ ៥៦ ដល់ ៥៨។

[17] សារអេឡិកត្រូនិចពី Roger PHILLIPS ជាមន្ត្រីច្បាប់ និងជាក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "កម្មវត្ថុ៖ ទម្រង់នៃការឆ្លើយតបទៅនឹងពាក្យសុំរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤)", ផ្ញើថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៣ នៅម៉ោង ៣:១៥ រសៀល, ឯកសារ E280/1។

[18] *សំណើលើកទី២ សុំដាក់បញ្ចូលអត្ថបទដកស្រង់ចេញពីសៀវភៅលោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល,* ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣, ឯកសារ E280/2។

[19] បណ្តឹងសាទុក្ខ, កថាខណ្ឌ ១២។

[20] បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៤។

ជំទាស់ បង្គាប់ឲ្យដោះលែង ខៀវ សំផន ជាបន្ទាន់ និងចេញដីកាស្ដីពីការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលចាំបាច់[21]។

10. នៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានឆ្លើយតបថា បណ្ដឹងសាទុក្ខមិនអាចទទួលយកបាន ដោយសារវាពុំត្រូវបានដាក់នៅក្នុងពេលវេលាកំណត់ជាធរមាន[22]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមថា មេធាវីការពារក្ដីពុំបានបង្ហាញថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងមានតម្លៃដែលនាំឲ្យមានសំណួមពរទេ[23]។ ហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តាបដិសេធបណ្ដឹងសាទុក្ខនេះទាំងស្រុង[24]។

## គ. ទឡ្ហីករណ៍ផ្ទាល់មាត់

11. មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលរៀបចំសវនាការជាសាធារណៈលើបណ្ដឹងសាទុក្ខ[25]។ វិធាន ១០៩(១) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។ ដោយបានពិចារណាទៅលើសារណាជាលាយលក្ខណ៍អក្សរយ៉ាងទូលំទូលាយដែលភាគីនានាបានដាក់ អង្គជំនុំជម្រះតុលាការកំពូលយល់ថា ពុំចាំបាច់រៀបចំសវនាការជាសាធារណៈលើបណ្ដឹងសាទុក្ខក្នុងករណីនេះទេ ហើយចេញសេចក្ដីសម្រេចរបស់ខ្លួនដូចខាងក្រោម។

[21] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៧៩។

[22] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើសុំដោះលែងឲ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារ E275/2/2 ("ចម្លើយតប"), កថាខណ្ឌ ១២ ដល់ ១៤។

[23] ចម្លើយតប, កថាខណ្ឌ ២៦ ដល់ ៤៧។

[24] ចម្លើយតប, កថាខណ្ឌ ៤៨។

[25] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៧៩។

### ឃ. អំឡុងពេលដែលអាចអនុវត្តតាមច្បាប់

12. សេចក្តីសម្រេចនេះ បានចេញទៅតាមពេលវេលាកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុង និង សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ[26]។ អនុលោមតាមវិធាន ១០៨(*៤ស្ទួន*)(ក) នៃវិធានផ្ទៃក្នុង បណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចស្តីពីការឃុំខ្លួន និងការដាក់ឱ្យត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវចេញក្នុងរយៈពេលបីខែ "បន្ទាប់ពីទទួលបាននូវសំណុំរឿងដោយភ្ជាប់ជាមួយនូវឯកសារថតចម្លងនៃសេចក្តីសម្រេច និងបណ្តឹងសាទុក្ខនីមួយៗ"[27]។

13. បណ្តឹងសាទុក្ខនេះ បានដាក់ និងជូនដំណឹងជាភាសាបារាំង នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៣ ហើយការបកប្រែជាភាសាខ្មែរ ត្រូវបានដាក់ និងជូនដំណឹងនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៣[28]។ មាត្រា ៧.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ចែងថា "គ្រប់ឯកសារទាំងអស់ ត្រូវដាក់ជាភាសាខ្មែររួមជាមួយអង់គ្លេស និង/ឬ បារាំង"។ គោលបំណងនៃលក្ខខណ្ឌនេះ គឺដើម្បីអនុញ្ញាតឱ្យស្ថាប័នជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនៃ អ.វ.ត.ក អាចពិនិត្យមើលលើឯកសារទាំងនេះបានត្រឹមត្រូវ។ ដូច្នេះ "ការទទួលឯកសារ"របស់អង្គជំនុំជម្រះតុលាការកំពូល អនុលោមតាមវិធាន ១០៨(២) និង ១០៨(*៤ស្ទួន*)(ក) នៃ វិធានផ្ទៃក្នុង បានទទួលនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៣។ ហេតុនេះ កាលបរិច្ឆេទរយៈពេលបីខែ ដែលកំណត់ដោយច្បាប់សម្រាប់ការចេញសេចក្តីសម្រេចនេះ គឺត្រឹមថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣។

## II. បទដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ

14. អនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង មានតែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដូចតទៅនេះតែប៉ុណ្ណោះដែលបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗ៖ (ក) សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី។ (ខ) សេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ

---

[26] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក វិសោធនកម្មលើកទី ៨ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១ ("វិធានផ្ទៃក្នុង"), សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក វិសោធនកម្មលើកទី ៨ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១២ ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")។

[27] សូមមើល វិធាន ១០៨(២) នៃវិធានផ្ទៃក្នុង។

[28] មេធាវីការពារបានស្នើសុំពីដំបូង ហើយបានទទួលការអនុញ្ញាតសមស្រប ដោយអនុលោមតាមវិធាន ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ក្នុងការដាក់បណ្តឹសាទុក្ខដំបូងជាភាសាបារាំងតែប៉ុណ្ណោះ ដោយឯកសារបកប្រែជាភាសាខ្មែរត្រូវដាក់ឱ្យបានឆាប់រហ័សបំផុត។ *សូមមើលខាងលើ* កថាខណ្ឌ ១៧។

តាមផ្លូវតុលាការអនុលោមតាមវិធាន ៨២។ (គ) សេចក្ដីសម្រេចអំពីវិធានការការពារតាមវិធាន ២៩(៤) (គ)។ និង (ឃ) សេចក្ដីសម្រេចស្ដីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥ (៦) នៃវិធានផ្ទៃក្នុង។ សេចក្ដីសម្រេចផ្សេងទៀតអាចប្ដឹងសាទុក្ខបានតែក្នុងករណីដែលបានធ្វើឡើងស្របពេលជាមួយបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្ដីតែប៉ុណ្ណោះ។

15. អនុលោមតាមវិធាន ១០៤(១) និងវិធាន ១០៥(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖ (ក) កំហុសលើអង្គច្បាប់ដែលនាំឱ្យមោឃៈសាលក្រមលើអង្គសេចក្ដី ឬសេចក្ដីសម្រេចនោះ។ (ខ) កំហុសនៃអង្គហេតុដែលនាំឱ្យសាលក្រមលើអង្គសេចក្ដី ឬសេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌។ ឬ (គ) ការភ័ន្តច្រឡំដែលស្ដែងចេញពីការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ។

## III. ភាពអាចទទួលយកបាន

### ក. ភាពទាន់ពេលវេលា

16. សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្ដឹងសាទុក្ខជាភាសាខ្មែរត្រូវបានដាក់ហួសរយៈពេលប្រាំ (៥) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទកំណត់ដាក់ឯកសារ[29]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា "បើសិនជាបណ្ដឹងសាទុក្ខមិនបានដាក់ទាន់ពេលវេលា ឬបើសិនជាមេធាវីការពារក្ដីមិនបានស្នើសុំនូវវិធានការពិសេស ឬ មិនបានជូនដំណឹងឱ្យអង្គជំនុំជម្រះ ឬ ភាគីផ្សេងទៀតបានជ្រាបអំពីការពន្យារពេលរបស់ខ្លួន ឬព្រមជាមួយនឹងការបញ្ជាក់ពីមូលហេតុឱ្យបានត្រឹមត្រូវទេនោះ បណ្ដឹងសាទុក្ខនេះគួរតែត្រូវបានចាត់ទុកថាមិនទាន់ពេលវេលា អាស្រ័យហេតុនេះ គួរតែត្រូវបានបដិសេធចោល"[30]។

17. នៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ មេធាវីការពារក្ដីបានស្នើសុំអនុញ្ញាតអនុលោមតាមប្រការ ៧.២ នៃសេចក្ដីណែនាំអនុវត្តន៍ ស្ដីពីការដាក់ឯកសារ ដើម្បីដាក់បណ្ដឹងសាទុក្ខជាភាសាបារាំងសិន ហើយ

[29] ចម្លើយតប កថាខណ្ឌ ១២។

[30] ចម្លើយតប កថាខណ្ឌ ១២-១៣។

នឹងដាក់បណ្តឹងសាទុក្ខនេះជាភាសាខ្មែរតាមក្រោយឲ្យបានលឿនបំផុត[31]។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា មេធាវីការពារក្តីបានបង្ហាញត្រឹមត្រូវអំពីកាលៈទេសៈពិសេសដែលតម្រូវឲ្យមានការអនុញ្ញាតដូច្នេះ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របតាមសំណើសុំនេះដោយឲ្យដាក់នៅក្នុងថ្ងៃតែមួយ[32]។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សំណើសុំនិងលិខិតប្រគល់សិទ្ធិដែលបានធ្វើឡើងក្នុងទម្រង់ជាសារអេឡិកត្រូនិច ពុំបានជូនដំណឹងឲ្យភាគីបានដឹងនោះទេ។ សំណើសុំ និងសេចក្តីសម្រេចស្រដៀងគ្នានាពេលខាងមុខត្រូវបញ្ចូលភាគីដែលមានផលប្រយោជន៍ទាំងអស់ផង ដើម្បីជៀសវាងការភ័ន្តច្រឡំស្រដៀងគ្នានេះនៅពេលខាងមុខ។

## ខ. វិធាន ១០៤(៤)(ខ) នៃវិធានផ្ទៃក្នុង

18. យើងពុំមានវិវាទណាមួយដែលថាបណ្តឹងសាទុក្ខនេះអាចទទួលយកបានអនុលោមតាមវិធាន ១០៤(៤)(ខ) នៃវិធានផ្ទៃក្នុង ដែលចែងថា "សេចក្តីសម្រេច[របស់អង្គជំនុំជម្រះសាលាដំបូង]អំពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអនុលោមតាមវិធាន ៨២ [បើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗ]"[33]។

19. វិធាន ៨២ នៃវិធានផ្ទៃក្នុងចែងអំពីនីតិវិធីស្តីពីការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន និងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនៅ អ.វ.ត.ក។ វិធាន ៨២(៥) នៃវិធានផ្ទៃក្នុងចែងថា "រាល់សេចក្តីសម្រេចទាំងអស់របស់អង្គជំនុំជម្រះសាលាដំបូង ដែលទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្នត្រូវបើកផ្លូវប្តឹងសាទុក្ខ ដែលធ្វើឡើងដោយជនជាប់ចោទ ឬ សហព្រះរាជអាជ្ញា តាមករណីសមស្រប"។ សេចក្តីសម្រេចដែលត្រូវបានជំទាស់ត្រូវ បានធ្វើឡើងអនុលោមតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង[34]។

---

[31] សារអេឡិកត្រូនិចពីលោកស្រី Marie CAPOTORTO ទីប្រឹក្សាច្បាប់សម្រាប់ក្រុមមេធាវីការពារក្តី ចំណងជើងថា "*demande d'autorisation de dépôt dans un premier temps en français*" ផ្ញើនៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ វេលាម៉ោង ៩:៣២ ព្រឹក។

[32] សារអេឡិកត្រូនិចពីលោកស្រី Sheila PAYLAN មន្ត្រីច្បាប់ និងក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូល ចំណងជើងថា "*demande d'autorisation de dépôt dans un premier temps en français*" ផ្ញើនៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ វេលាម៉ោង ៩:៤៣ ព្រឹក។

[33] *សូមមើល*ចម្លើយតប, កថាខណ្ឌ ១១។

[34] *សូមមើល*សេចក្តីសម្រេចដែលត្រូវបានជំទាស់ ,កថាខណ្ឌ ១៤, ២៣។ សេចក្តីសម្រេចដែលត្រូវបានជំទាស់ក៏ត្រូវបានចេញអនុលោមតាមវិធាន ៦៣ នៃវិធានផ្ទៃក្នុង ដែលចែងអំពីនីតិវិធីស្តីពីការឃុំខ្លួនបណ្តោះអាសន្ន។ *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១៣។

20. ហេតុដូច្នេះ បណ្តឹងសាទុក្ខនេះអាចទទួលយកបានអនុលោមតាមវិធាន ១០៤(៤)(ខ) នៃវិធានផ្ទៃក្នុង។

## IV. អង្គសេចក្តី

21. មេធាវីការពារក្តីបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង៖ (ក) មិនបានបង្ហាញពីភាពចាំបាច់សម្រាប់ការបន្តការឃុំខ្លួន, (ខ) មិនបានដោះស្រាយសំណុំរឿង ប្រឆាំងខៀវ សំផន ដោយការប្រុងប្រយ័ត្ន និងមិនបានទទួលស្គាល់ពីរយៈពេលនៃការឃុំខ្លួនគាត់ ដែលមិនមានសមាមាត្រសមស្រប និង (គ) កំហុសឆ្គងក្នុងការពិចារណាថាតើមានការផ្លាស់ប្តូកាលៈទេសៈដែរឬទេ បន្ទាប់ពីមានសំណើចុងក្រោយរបស់គាត់សុំឲ្យដោះលែង[35]។

22. អង្គជំនុំជម្រះតុលាការកំពូល នឹងធ្វើការដោះស្រាយទៅលើបញ្ហាទាំងអស់នេះតាមលំដាប់លំដោយ។

### ក. ការចោទប្រកាន់ ថាខកខានមិនបានបង្ហាញពីភាពចាំបាច់សម្រាប់ការបន្តការឃុំខ្លួន

23. នៅពេលដែលបានធ្វើការច្រានចោលសំណើសុំដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយបានបង្គាប់ឲ្យបន្តឃុំខ្លួន ខៀវ សំផន ជាបណ្តោះអាសន្នទៀតនោះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សម្អាងហេតុដូចតទៅនេះ៖

<u>ការពិចារណាជាបឋមរបស់អង្គជំនុំជម្រះសាលាដំបូងគឺហានិភ័យ ដែលជនជាប់ចោទអាចរត់គេច</u>។ ជនជាប់ចោទយល់ព្រមបង្ហាញវត្តមានក្នុងអំឡុងសវនាការរបស់គាត់ និងគោរពលក្ខខណ្ឌនានាដែលអាចត្រូវបានដាក់ ប្រសិនបើគាត់ទទួលបានការដោះលែងជាបណ្តោះអាសន្ន។ គ្រួសាររបស់គាត់បានគូសបញ្ជាក់ថា ខ្លួននឹងផ្តល់ឲ្យគាត់នូវកន្លែងស្នាក់អាស្រ័យ ការធ្វើដំណើរ និងជួយដល់គាត់ក្នុងការបំពេញលក្ខខណ្ឌនៃការដោះលែង រួមទាំងការបង្ហាញខ្លួនសម្រាប់សវនាការ។ <u>អង្គជំនុំជម្រះកត់សម្គាល់ទៀតថាសំណុំរឿង ០០២/០១ កំពុងចូលដល់ដំណាក់កាលបិទបញ្ចប់ ហើយការមិនបង្ហាញខ្លួនរបស់ជនជាប់ចោទ (ទោះជាដោយចេតនា ឬដោយអចេតនាក្តី) ប្រថុយប្រថានថានឹងមានការពន្យារពេលចំពោះការបញ្ចប់សំណុំរឿង ០០២/០១ ឱ្យបានឆាប់រហ័ស និងការជំនុំជម្រះក្តីបន្តបន្ទាប់ទៀត</u>ឲ្យបានទាំងស្រុង “[...] គឺជាកិច្ចការដែលត្រូវត្រៀមរៀបចំយ៉ាងធំធេង និង ភស្តុភារយ៉ាងច្រើនដែលទាក់ទងនឹងជនជាប់ចោទទាំងបួនរូប [បច្ចុប្បន្នមានពីររូប] ដែលអ្នកទាំងនោះភាគច្រើនមានបញ្ហាសុខភាព និងមានដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្រើនសន្ធឹកសន្ធាប់ និងក្រុមមេធាវីជាច្រើននាក់”។ អង្គជំនុំជម្រះពុំយល់ឃើញថា ការធានាអះអាងរបស់ជនជាប់ចោទ និងសមាជិកគ្រួសាររបស់គាត់មានភាពគ្រប់គ្រាន់ដើម្បីបំបាត់កង្វល់ទាំងនេះ ឬហានិភ័យ បើទោះជាតិចតួចក៏ដោយ ដែលថាជនជាប់ចោទអាចរត់គេចខ្លួន នៅក្នុងដំណាក់កាលចុងក្រោយនៃសវនាការនេះឡើយ។ <u>អង្គជំនុំជម្រះក៏កត់សម្គាល់ផងដែរថា នៅដំណាក់កាលចុងក្រោយនៃសវនាការនេះ ជនជាប់ចោទអាចពិចារណាដល់ការរត់គេចខ្លួន</u> ថាជាជម្រើសជាក់លាក់មួយនៅពេលដែលប្រឈមនឹងការទទួលទោសក្នុងពន្ធនាគាររយៈពេលវែង

[35] បណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥-៧៨។

ប្រសិនបើគាត់ត្រូវបានរកឃើញថាមានពិរុទ្ធ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការពិចារណាទាំងនេះនៅតែជាមូលហេតុដែលមានសុពលភាពដើម្បីបន្តឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន[36]។

24. មេធាវីការពារក្តីបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មិនបានផ្តល់សំអាងហេតុឲ្យបានគ្រប់គ្រាន់ចំពោះសេចក្តីសម្រេចរបស់ខ្លួន ដោយផ្តល់ភាពសំខាន់ដែលមិនត្រឹមត្រូវចំពោះហានិភ័យក្នុងការរត់គេចតាមការសន្និត និងការប្រឈមក្នុងកិច្ចការរៀបចំ ហើយមិនគិតពិចារណាទៅលើកាលៈទេសៈផ្ទាល់ខ្លួនរបស់ ខៀវ សំផន ព្រមទាំងលក្ខខណ្ឌនៃការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលបានស្នើឡើង ព្រមទាំងផ្តល់ទម្ងន់ដោយមិនគ្រប់គ្រាន់ទៅលើការធានាដែលគាត់បានផ្តល់ឲ្យ[37]។

25. សហព្រះរាជអាជ្ញាបានឆ្លើយតបថា មេធាវីការពារក្តី មិនបានបង្ហាញពីកំហុសឆ្គងណាមួយនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលសម្រេចថាការឃុំខ្លួន ខៀវ សំផន បន្តគឺនៅតែជាការចាំបាច់នោះ[38]។

26. អង្គជំនុំជម្រះតុលាការកំពូលសូមរំឭកថា ច្បាប់គ្រប់គ្រងទៅលើការឃុំខ្លួននៅ អ.វ.ត.ក ដែលស្របទៅតាមបទដ្ឋានអន្តរជាតិនោះ គឺផ្អែកលើការសន្និតទុកជាមុននូវសិទ្ធិទទួលបានសេរីភាព លក្ខខណ្ឌតម្រូវនៃនីត្យានុកូលភាព និងការហាមឃាត់ការចាប់ឃុំខ្លួនតាមអំពើចិត្ត[39]។ អាស្រ័យហេតុនេះ ក្នុងការពិចារណាទៅលើបញ្ហានៃការឃុំខ្លួនបន្ត អង្គជំនុំជម្រះនានារបស់ អ.វ.ត.ក ត្រូវតែធានាថាការឃុំខ្លួនត្រូវតែផ្អែកលើមូលដ្ឋានច្បាប់នៅគ្រប់ពេលទាំងអស់[40]។ ជនណាម្នាក់ដែលត្រូវបានឃុំខ្លួនពីការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ត្រូវតែទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប ឬក៏ត្រូវដោះលែង ហើយការឃុំ

---

[36] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១ (ការដកស្រង់ផ្នែកខាងក្នុង ត្រូវបានដកចេញ ហើយមានការបញ្ជាក់បន្ថែម)

[37] បណ្តឹងសាទុក្ខ កថាខណ្ឌ ១៣ ដល់ ៤៥។

[38] ចម្លើយតប កថាខណ្ឌ ២៧ ដល់ ៣៤។

[39] *សូមមើល* សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៤៦ និងឯកសារយោងដែលបានដកស្រង់ក្នុងកថាខណ្ឌនោះ។

[40] *សូមមើល* សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៤៦ ដែលបានដកស្រង់មាត្រា ៩(១) នៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ (“ការដកហូតសេរីភាព មិនត្រូវបានអនុញ្ញាតឡើយលើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់”) ហើយកថាខន្ឌ ៤៧ (“ការសន្និតទុកជាមុននៃសិទ្ធិមានសេរីភាពនេះ តម្រូវថាការឃុំខ្លួនជនជាប់ចោទ គ្រប់ករណីទាំងអស់ ត្រូវតែមានមូលដ្ឋាននៅក្នុងសេចក្តីសម្រេចរបស់តុលាការ ដែលត្រូវចេញឲ្យស្របតាមនីតិវិធី និងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់”)។

ខ្លួនមនុស្សដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ[41]។ ហេតុដូច្នេះ អង្គជំនុំជម្រះនានា ត្រូវតែពិនិត្យទៅលើអង្គហេតុទាំងអស់ដែលលើកឡើងជាការគាំទ្រ ឬជាការប្រឆាំង ទៅនឹងអត្ថិភាពនៃលក្ខខណ្ឌតម្រូវត្រឹមត្រូវនៃផលប្រយោជន៍សាធារណៈ ដោយធៀបជាមួយការពិចារណាដោយត្រឹមត្រូវទៅលើគោលការណ៍សច្ចធារណ៍នៃនិរទោស ថាជាការឃ្លាតចាកពីវិធាននៃការគោរពដល់សិទ្ធិសេរីភាពរបស់បុគ្គល និងការសន្មតទុកជាមុននូវការទទួលបានការដោះលែង[42]។ ចុងក្រោយ អង្គជំនុំជម្រះ ត្រូវបង្ហាញអង្គហេតុទាំងនេះនៅក្នុងសេចក្តី សម្រេចរបស់ខ្លួន លើសំណើសុំការដោះលែង[43]។

27. វិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង ចែងថាដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នអាចចេញបានតែក្នុងករណីដែលបំពេញបានតាមលក្ខខណ្ឌចំនួនពីរ។ លក្ខខណ្ឌទីមួយគឺមានចែងក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង ដែលតម្រូវថាមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនដែលត្រូវឃុំខ្លួននោះ ធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន។ លក្ខខណ្ឌទីពីរដែលមានចែងក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ដែលតម្រូវថាការឃុំខ្លួនបណ្តោះអាសន្ន អាចចាត់ទុកជាវិធានការចាំបាច់ ដើម្បីបំពេញបានយ៉ាងតិចនូវមូលដ្ឋានមួយ ក្នុងចំណោមមូលដ្ឋានទាំងប្រាំ ដូចរៀបរាប់ខាងក្រោម (១) រារាំងកុំឲ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, (២) ថែរក្សាភស្តុតាង ឬការពារមិនឲ្យបំផ្លាញភស្តុតាង, (៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទ នៅក្នុងដំណើរការនីតិវិធី, (៤) ការពារសន្តិសុខឲ្យជនដែលត្រូវចោទ ឬ (៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ។

28. វិធាន ៨២(១) នៃវិធានផ្ទៃក្នុងចែងថា "ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលចូលខ្លួនលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដែលរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវបានសម្រេចសេចក្តី លើកលែងតែករណីដែលមានចែងក្នុងអនុវិធាន ២ ខាងក្រោម។ វិធាន ៨២(២) នៃវិធានផ្ទៃក្នុងចែងថា "គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះអាចបង្គាប់ឲ្យដោះលែងជនជាប់ចោទ ឬដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងករណីចាំបាច់ ឬបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទបាន ស្របតាមវិធានផ្ទៃក្នុងនេះ"។ ទោះជាយ៉ាងណាក៏

---

[41] *សូមមើល* សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៤៦ ដែលដកស្រង់មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ។

[42] *សូមមើល* សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៤៦ និង *ឯកសារយោងដែលបានដកស្រង់ក្នុងកថាខណ្ឌនោះ*។

[43] សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូលលើការដោះលែងជាបន្ទាន់ កថាខណ្ឌ ៤៦។

ដោយ អង្គជំនុំជម្រះតុលាការកំពូលសូមរំឮកថា វិធាន ៨២(១)នៃវិធានផ្ទៃក្នុង ចែងត្រឹមតែអនុញ្ញាតឱ្យបង្ហាញអំពី"គោលការណ៍នៃការសន្មតទុកជាមុនដែលថា លក្ខខណ្ឌសម្រាប់ការឃុំខ្លួនដែលបង្គាប់ពីមុនដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងនីតិវិធីតទល់ ហើយដែលមានការពិនិត្យឡើងវិញដោយអង្គបុរេជំនុំជម្រះ ត្រូវបន្តអនុវត្តនៅពេលដែលសំណុំរឿងបញ្ជូនទៅជំនុំជម្រះ[44]។ ដោយហេតុថា នេះជាបន្ទុករបស់ជនជាប់ចោទក្នុងការជំទាស់ទៅលើទឡ្ហីករណ៍ទាំងនេះនៅក្នុងសំណើសុំការដោះលែង[45] អង្គជំនុំជម្រះសាលាដំបូង មានកាតព្វកិច្ចធ្វើការពិនិត្យមើល"ដោយមានអត្ថន័យ" នៅពេលដែលខ្លួនពិនិត្យឡើងវិញនូវលក្ខខណ្ឌសម្រាប់ការឃុំខ្លួន[46]។

29. ដោយហេតុថា ភាពមន្ទិលសង្ស័យដែលមានភស្តុតាងគាំទ្រ និងលក្ខខណ្ឌជាក់លាក់សម្រាប់ការឃុំខ្លួន ពុំមែនជាធាតុដែលមានលក្ខណៈប្រកដប្រជានោះ ទើបធាតុទាំងនេះ គប្បីត្រូវទទួលការវាយតម្លៃយ៉ាងម៉ត់ចត់ នៅរាល់ពេលធ្វើការពិនិត្យឡើងវិញ ដើម្បីឱ្យស្របទៅតាមគោលការណ៍នៃការសន្មតទុកជាមុន ដែលជាប្រយោជន៍សេរីភាព។ កត្តានេះពិចារណាឃើញថា អង្គជំនុំជម្រះនៃ អ.វ.ត.ក មិនអាចនឹងមិនអើពើលើអង្គហេតុ ដែលកើតមាននៅក្នុងកិច្ចដំណើរការនីតិវិធី ដោយពុំគិតថា តើ អង្គហេតុទាំងនេះត្រូវបានលើកឡើងដោយម្ចាស់បណ្តឹងសាទុក្ខ ដែរ ឬយ៉ាងណា និងថា តើ នឹងមានការជះឥទ្ធិពលដល់លក្ខខណ្ឌនៃការឃុំខ្លួន ដែរ ឬយ៉ាងណា នោះទេ។ ក្នុងសំណុំរឿងបច្ចុប្បន្ន កត្តាទាំងពីរនេះ គឺអាស្រ័យទៅតាមការកន្លងផុតនៃពេលវេលា និងដំណាក់កាលចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ បន្ទាប់ពីរយៈពេលពីរឆ្នាំនៃការជំនុំជម្រះ និងការតវ៉ាក្តី ការសំអាងតែមួយគត់របស់អង្គជំនុំជម្រះសាលាដំបូងទៅលើការរកឃើញនៃសំអាងហេតុ នៅក្នុងដំណាក់កាលស៊ើបអង្កេត និងជំនុំជម្រះ ដោយពុំមានការវាយតម្លៃលើភាពជាក់ស្តែង[47] គឺមានលក្ខណៈប្រថុយនឹងភាពធ្វើតាមអំពើចិត្ត។ កត្តាជាប់ពាក់ព័ន្ធមួយផ្សេងទៀត គឺសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ដែលបានធ្វើឡើងនៅពេលចេញសេចក្តីសម្រេច ដែលរងការជំទាស់នេះ ហើយបានតម្រូវថា លក្ខខណ្ឌសម្រាប់ការឃុំខ្លួន ត្រូវតែធ្វើការវាយតម្លៃ ទាក់ទងទៅនឹងសំណុំរឿងនីមួយៗដែលបានបំបែកនោះ។

---

[44] សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូលលើការដោះលែងជាបន្ទាន់ កថាខណ្ឌ ៤៧។

[45] សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូលលើការដោះលែងជាបន្ទាន់ កថាខណ្ឌ ៤៨។

[46] សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូលលើការដោះលែងជាបន្ទាន់ កថាខណ្ឌ ៤៩។ ការផ្អែកលើគោលការណ៍សន្មត់ទុកជាមុននៃការឃុំខ្លួន ពេញមួយដំណាក់កាលជំនុំជម្រះទាំងមូល បញ្ហាថាតើ ត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីដំណើរការនីតិវិធីព្រហ្មទណ្ឌ ឬកើតចេញពីការអនុវត្តដែលបានបង្កើត គឺផ្ទុយទៅនឹងការហាមឃាត់នូវភាពធ្វើតាមអំពើចិត្ត។

[47] *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៦។

30. សិទ្ធិទទួលបានសេចក្ដីសម្រេចដោយមានសំអាងហេតុ ត្រូវបានទទួលស្គាល់ជាសាកល នៅក្នុងយុត្តិសាស្ត្រស្ដីពីសិទ្ធិមនុស្ស និងមានចែងយ៉ាងជាក់លាក់ក្នុងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[48]។ វិសាលភាពនៃកាតព្វកិច្ចក្នុងការផ្ដល់សំអាងហេតុ មានលក្ខណៈប្រែប្រួលទៅតាមប្រភេទនៃសេចក្ដីសម្រេច និងត្រូវបានកំណត់ទៅតាមកាលៈទេសៈនៃរឿងក្ដី។ នៅពេលតុលាការពុំតម្រូវឱ្យផ្ដល់ចម្លើយលម្អិតចំពោះទឡ្ហីករណ៍នីមួយៗដែលបានលើកឡើងនោះ ចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នៅក្នុងសេចក្ដីសម្រេចថា បញ្ហាសំខាន់នៃសំណុំរឿងនេះ ត្រូវបានដោះស្រាយរួចហើយ[49]។ នៅពេលដែលពុំចាំបាច់ធ្វើការពិចារណាលើបញ្ហាថា តើ កាតព្វកិច្ចក្នុងការផ្ដល់សំអាងហេតុ មានចែងក្នុងច្បាប់ស្ដីពីនីតិវិធីដែរ ឬយ៉ាងណានោះ និងដោយពុំចាំបាច់ពិចារណាលើបញ្ហាថា តើមានសំអាងហេតុជាក់ស្ដែងក្នុងការធ្វើយុត្តិកម្មការឃុំខ្លួនដែរ ឬយ៉ាងណានោះ វាជាការផ្ទុយទៅនឹងគោលការណ៍នៃការការពារមិនឱ្យមានភាពធ្វើតាមអំពើចិត្ត ប្រសិនបើស្ថាប័នតុលាការមានសមត្ថកិច្ច នៅពេលសម្រេចបង្គាប់ការបន្តការឃុំខ្លួន បានខកខានផ្ដល់ទឡ្ហីករណ៍គាំទ្ររបស់ខ្លួន[50] ផ្ដល់តែសំអាងហេតុដែលមានលក្ខណៈ"ច្បោលៗមិនស៊ីជម្រៅ"

---

[48] សិទ្ធិទទួលបានសេចក្ដីសម្រេចដែលមានសំអាងហេតុ មានចែងយ៉ាងច្បាស់លាស់នៅចំពោះមុខ តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស ("ECtHR"), តុលាការអន្តរទ្វីបអាមេរិកស្ដីពីសិទ្ធិមនុស្ស គណៈកម្មការអាហ្វ្រិកស្ដីពីសិទ្ធិមនុស្ស និងប្រជាជន, គណៈកម្មាធិការអង្គការសហប្រជាជាតិស្ដីពីសិទ្ធិមនុស្ស("HRC"), តុលាការព្រហ្មទណ្ឌអន្តរជាតិ("ICC"), តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី("ICTY"), តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា("ICTR"), និង អ.វ.ត.ក។ *សូមមើល ជាទូទៅ*, ICC, សាលដីកាលើបណ្ដឹងសាទុក្ខរបស់ Mr Laurent Koudou Gbagbo ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១២ ចំណងជើងថា "សេចក្ដីសម្រេចលើ 'Requête de la Défense demandant la mise en liberté provisoire du président Gbagbo'", ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១២, ICC-02/11-01/11-278-Red, មតិជំទាស់របស់ចៅក្រម Anita Ušacka, កថាខណ្ឌ ៨ ដល់ ១៤ និង ឯកសារយោងដែលបានដកស្រង់នៅទីនោះ ។

[49] *សូមមើល ឧ.* ECtHR, *រឿងក្ដី Hadjianastassiou ទល់នឹង Greece*, សាលក្រម ចុះថ្ងៃទី ១៦ ខែ ធ្នូ ១៩៩២ សំណើសុំលេខ 12945/87, កថាខណ្ឌ ៣៣; *រឿងក្ដី Ruiz Torija ទល់នឹង Spain*, សាលក្រម, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៤, សំណើសុំលេខ 18390/91, កថាខណ្ឌ ២៩; *រឿងក្ដី Van de Hurk ទល់នឹង the Netherlands*, សាលក្រម, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៤, សំណើសុំលេខ 16034/90, កថាខណ្ឌ ៦១; *រឿងក្ដី Taxquet ទល់នឹង Belgium*, សាលក្រម, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១០, សំណើសុំលេខ 926/05, កថាខណ្ឌ ៩០ ដល់ ៩១។

[50] *សូមមើល* ECtHR, *រឿងក្ដី Khudoyorov ទល់នឹង Russia*, សាលក្រម, ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥, សំណើសុំលេខ 6847/02, កថាខណ្ឌ ១៣៦; *រឿងក្ដី Stasaitis ទល់នឹង Lithuania*, សាលក្រម, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០២, សំណើសុំលេខ 47679/99, កថាខណ្ឌ ៦៧ និង ឯកសារយោងដែលបានដកស្រង់នៅទីនោះ។

ដែលពុំបានផ្តល់នូវសេចក្តីលម្អិតនៃការពិចារណាលើអង្គហេតុ ដែលជាប់ពាក់ព័ន្ធ[51] ឬ ផ្អែកតែទៅលើគោលការណ៍នៃការសន្និត់ទុកជាមុខ[52]។

31. នៅក្នុងសេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់នោះ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យបន្តឃុំខ្លួន ខៀវ សំផន ដោយផ្អែកលើមូលដ្ឋានតែមួយប៉ុណ្ណោះគឺ "ការដែល ខៀវ សំផន អាចប្រឈមនឹងការផ្តន្ទាទោសធ្ងន់ធ្ងរ ប្រសិនបើតុលាការរកឃើញថាគាត់មានពិរុទ្ធនោះ ខៀវ សំផន អាចមានចេតនាកាន់តែខ្លាំងក្នុងការរត់គេចខ្លួន"[53]។ អង្គជំនុំជម្រះសាលាដំបូងបដិសេធចោលលក្ខខណ្ឌដទៃទៀតទាំងអស់ដែលគាំទ្រដល់ការឃុំខ្លួនបន្ត[54]។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថាការច្រានចោលបែបនេះគឺធ្វើឡើងដោយមិនមានសម្អាងហេតុ[55] ហើយ "ការរំពឹងទុកជាមុនអំពីការដាក់ទោសធ្ងន់ធ្ងរមិនអាចធ្វើបានឡើយចំពោះជនជាប់ចោទ ក្នុងន័យមិនច្បាស់លាស់ ដែលជាកត្តាតែមួយគត់ក្នុងការកំណត់អំពីលទ្ធផលនៃពាក្យស្នើសុំដោះលែង ដោយហេតុថា ជនជាប់ចោទទាំងអស់នៅចំពោះមុខ អ.វ.ត.ក ប្រសិនបើមានពិរុទ្ធភាពនោះទំនងជាប្រឈមមុខនឹងការដាក់ទោសធ្ងន់ធ្ងរ"[56]។ ដោយហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងក្នុងការថ្លឹងថ្លែងដោយមិនសមស្រប អំពីសក្តានុពលភាពនៃការផ្តន្ទាទោសធ្ងន់ធ្ងរលើ ខៀវ សំផន ធ្វើជាយុត្តិកម្មនៃការឃុំខ្លួនគាត់បន្តទៀត នៅពេលនោះ[57], ដូច្នេះហើយ មិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់ ក្នុងការបង្គាប់បន្តឃុំខ្លួនជនជាប់ចោទតទៅទៀត ដោយអនុលោមតាមវិធាន ៦៣(៣)(ខ)(៣) នៃវិធានផ្ទៃក្នុង[58]។

---

[51] តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR), *រឿងក្តី I.A ទល់នឹង France*, សាលក្រម, ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៨, សំណើសុំលេខ 28213/95, កថាខណ្ឌ ១០៥។

[52] *សូមមើល ក្នុងចំណោម*, ECtHR, *រឿងក្តី Belchev ទល់នឹង Bulgaria*, សាលក្រម ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០៤, សំណើសុំលេខ 39270/98, កថាខណ្ឌ ៧៦ ដល់ ៧៩; *រឿងក្តី Ilijkov ទល់នឹង Bulgaria*, សាលក្រម, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០១, សំណើសុំលេខ 33977/96, កថាខណ្ឌ ៨៧; *រឿងក្តី Jecius ទល់នឹង Lithuania*, សាលក្រម, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០, សំណើសុំលេខ 34578/97, កថាខណ្ឌ ៩៣ ដល់ ៩៤។

[53] សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៤០។

[54] សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៤០។

[55] សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៣៨។

[56] សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៤០។

[57] សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៤១។ *សូមមើលផងដែរ* សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៥០។

[58] សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៥៤។

32. មេធាវីការពារក្ដីបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសឆ្គងដដែលម្ដងទៀត ដោយលើកយកហានិភ័យនៃការរត់គេចខ្លួនតាមការស្មាន ថាជាការពិចារណាចម្បង សម្រាប់ការបង្គាប់ឲ្យឃុំខ្លួន ខៀវ សំផន បន្ត ហើយអង្គជំនុំជម្រះសាលាដំបូងមិនបានផ្ដល់សំអាងហេតុគ្រប់គ្រាន់សម្រាប់សេចក្ដីសម្រេចនេះទេ[59]។ អង្គជំនុំជម្រះតុលាការកំពូលសូមកត់សម្គាល់ថា នៅក្នុងសេចក្ដីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងវិញពីការពិចារណារបស់ខ្លួនដែលថា “នៅដំណាក់កាលចុងក្រោយនៃសវនាការនេះ ជនជាប់ចោទអាចពិចារណាដល់ការរត់គេចខ្លួន ថាជាជម្រើសជាក់លាក់មួយនៅពេលដែលប្រឈមនឹងការទទួលទោសក្នុងពន្ធនាគាររយៈពេលវែង ប្រសិនបើគាត់ត្រូវបានរកឃើញថាមានពិរុទ្ធ”[60] ហើយបានបដិសេធដដែលៗឡើងវិញ ចំពោះលក្ខខណ្ឌដទៃទៀតដែលមានចែងក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ដែលអាចធ្វើជាយុត្តិកម្មសម្រាប់ការបន្តឃុំខ្លួនគាត់[61]។ មានសមាសធាតុបន្ថែមតែមួយគត់ក្នុងពេលនេះគឺ “សំណុំរឿង ០០២/០១ ឈានចូលដល់ដំណាក់កាលចុងក្រោយ”[62]។

33. ហានិភ័យនៃការរត់គេចខ្លួន គឺជាមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានស្របច្បាប់ដទៃទៀតជាច្រើនដែលអាចជាយុត្តិកម្មសម្រាប់ការបដិសេធការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[63]។ តាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក វិធាន ៦៣(៣)(ខ)(iii) នៃវិធានផ្ទៃក្នុង បានចែងយ៉ាងទូលំទូលាយដោយរួមបញ្ចូលមិនត្រឹមតែហានិភ័យនៃការរត់គេចខ្លួនប៉ុណ្ណោះទេ ថែមទាំងហានិភ័យនៃការមិនបង្ហាញខ្លួននៅក្នុងសវនាការទៀតផង[64]។ “សវនាការ” នៅក្នុងបរិបទនេះគឺអាចយល់បានថាជាកិច្ចដំណើរការនីតិវិធីទាំងស្រុង រហូតដល់ពេលបញ្ចប់សំណុំរឿង[65]។ ទោះជាយ៉ាងណាក៏ដោយ គ្រាន់តែបង្ហាញពីហានិភ័យទូទៅនៃការរត់ ការគេចខ្លួន ឬការរារាំងដល់កិច្ចដំណើរការនីតិវិធី គឺមិនគ្រប់គ្រាន់ឡើយ លុះត្រាតែបញ្ហាទាំងនេះមានមូលដ្ឋានផ្អែកលើកាលៈទេសៈពិសេសនៃសំណុំរឿងនៅចំពោះមុខ ដែលរារាំងដល់ការដោះលែង បើ

---

[59] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៤ ដល់ ១៩។

[60] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

[61] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២០, ២២។

[62] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

[63] *សូមមើល* សេចក្ដីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៤០ និងឯកសារយោងដែលបានដកស្រង់ក្នុងកថាខណ្ឌនោះ។

[64] វិធាន ៦៣(៣)(ខ)(iii) ចែងថាការបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើឡើងក្នុងករណីដែលមានភាពចាំបាច់សម្រាប់ “ធានាអំពីវត្តមានរបស់ [ជនដែលត្រូវឃុំខ្លួន] នៅក្នុងដំណើរការនីតិវិធី។

[65] សូមដកស្រង់ពាក្យជាភាសាបារាំងដែលមានអត្ថន័យដូចគ្នា ដែលចែងថា “តាមការសម្រេចរបស់ស្ថាប័នតុលាការ” ឬពាក្យប្រហាក់ប្រហែលគ្នានេះ។

ទោះបីជាការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយមានលក្ខខណ្ឌក៏ដោយ[66]។ ការវិនិច្ឆ័យទូទៅសម្រាប់ធ្វើយុត្តិកម្មលើការបដិសេធការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយផ្អែកលើមូលដ្ឋាននេះ គឺថា "ត្រូវតែមានកាលៈទេសៈពេញលេញ [...] ដែលអាចផ្តល់ជាសំអាងហេតុដើម្បីគាំទ្រថាផលវិបាក និងគ្រោះថ្នាក់នៃការរត់គេចខ្លួន គឺមានលក្ខណៈស្រាលជាង [ចំពោះជនជាប់ចោទ] ការបន្តនៅក្នុងការឃុំឃាំង"[67]។ យោងតាមកាលៈទេសៈទាំងនេះ ការរំពឹងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលវែងអាចចាត់ទុកថាជាកត្តាមួយ ក្នុងចំណោមកត្តាជាច្រើន សម្រាប់ការវាយតម្លៃថាតើ ជនសង្ស័យនឹងបង្ហាញខ្លួននៅក្នុងសវនាការ ដែរ ឬយ៉ាងណា ប្រសិនបើគេត្រូវបានដោះលែង។ ទោះបីជាយ៉ាងណាក៏ដោយ កត្តានេះមិនអាចប្រើប្រាស់ក្នុងលក្ខណៈ *មិនច្បាស់លាស់* ដែលជាកត្តាតែមួយគត់ក្នុងការបដិសេធការដោះលែងនោះទេ ប៉ុន្តែកត្តានេះត្រូវយកមកពិចារណាជាមួយកត្តាពាក់ព័ន្ធដទៃទៀត ដែលអាចបង្ហាញពីហានិភ័យដែលជាក់ច្បាស់ស្តីពីការរត់គេចខ្លួន[68]។ ជាការចាំបាច់ដែលត្រូវពិចារណាផងដែរថា ហានិភ័យនៃការរត់

---

[66] *សូមមើល* ECtHR, *រឿងក្តី Boicenco ទល់នឹង Moldova*, សាលក្រម, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៦, សំណើសុំលេខ 41088/05, កថាខណ្ឌ ១៤៣ ("ក្នុងសំណុំរឿងបច្ចុប្បន្ន, តុលាការកត់សម្គាល់ឃើញថា តុលាការជាន់ដំបូង និងតុលាការឧទ្ធរណ៍ នៅពេលដែលបង្គាប់បន្តការឃុំខ្លួនជនជាប់ចោទ បានដកស្រង់ច្បាប់ដែលពាក់ព័ន្ធ ដោយពុំបានបង្ហាញពីមូលហេតុដែលខ្លួនពិចារណាសម្រេចថា ការលើកឡើង មានភស្តុតាងគាំទ្រដែលថា ម្ចាស់ប្តឹងសាទុក្ខ រារាំងកិច្ចដំណើរការនីតិវិធី រត់គេចខ្លួន ឬប្រព្រឹត្តបទល្មើសឡើងវិញ។ តុលាការនេះ ពុំមានបំណងបដិសេធទឡ្ហីករណ៍ ដែលលើកឡើងដោយមេធាវីការពារក្តី។ ហេតុនេះ កាលៈទេសៈនៃសំណុំរឿងនេះ មានលក្ខណៈស្រដៀងគ្នាទៅនឹងកាលៈទេសៈទាំងនោះ [...] ក្នុងនោះ តុលាការនេះរកឃើញការរំលោភបំពានលើមាត្រា ៥ § ៣3 នៃសិទ្ធិសញ្ញាស្តីពីសំអាងហេតុដែលមិនគ្រប់គ្រាន់ ដែលផ្តល់ដោយតុលាការសំរាប់ការឃុំខ្លួនជនជាប់ចោទ [...] តុលាការសម្រេចពិចារណាឃើញថា វិធីសាស្ត្រដូចគ្នា ត្រូវបានយកមកប្រើនៅក្នុងសំណុំរឿងបច្ចុប្បន្ន" (សេចក្តីសម្រេចបញ្ជាក់បន្ថែម))។ *សូមមើល* HRC, *រឿងក្តី Smantser ទល់នឹង Belarus*, ទស្សនទាន, ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨, សំណើសុំលេខ 1178/2003, កថាខណ្ឌ 10.3; *រឿងក្តី Hill ទល់នឹង Spain*, ទស្សនទាន, ថ្ងៃទី ២ ខែ មេសា ១៩៩៧, សំណើសុំលេខ 526/1993, កថាខណ្ឌ ១២.៣។

[67] តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (EctHR), *Stogmuller ទល់នឹង. Austria* A 9 (1969); 1 EHRR 155 កថាខណ្ឌ ១៥។ *សូមមើលផងដែរ Smirnova ទល់នឹង Russia* 2003-IX; 39 EHRR 450, កថាខណ្ឌ ៦០។

[68] *សូមមើល* សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៤០ ព្រមទាំងឯកសារយោងដែលបានដកស្រង់នៅក្នុងកថាខណ្ឌនោះ។ សូមមើលផងដែរ ECHR, *Kononovich ទល់នឹង Russia,* No. 41169/02, ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ កថាខណ្ឌ ៥៥ និង ៥៦ ដែលតុលាការក្នុងស្រុក ត្រូវផ្តល់សក្ខីកម្មសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន "ដែលយោងជាសំខាន់ទៅលើស្ថានទម្ងន់នៃបទចោទប្រឆាំងអ្នកដាក់ពាក្យសុំ [...] ដែលបានបង្ហាញនៅក្នុងការផ្តន្ទាទោសគាត់កាលពីលើកមុន [...] ហើយបានសម្រេចស្របគ្នាថា ការដោះលែងជនជាប់ចោទ "អាចរារាំងដល់ដំណើរការពិនិត្យទាំងស្រុង គ្រប់ជ្រុងជ្រោយ និងដោយសត្យានុម័តទៅលើរឿងក្តី"។ តុលាការបានបដិសេធយុត្តិកម្មរបស់តុលាការជំនុំជម្រះ

គេចខ្លួន អាចថយចុះទៅតាមពេលវេលា ដោយសារតែ ឧទាហរណ៍ លក្ខណៈជាសាធារណៈនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ លទ្ធភាពដែលអាចកើតមានគឺថា សវនាការបានធ្វើឲ្យកើននូវហានិភ័យនៃការរត់គេចខ្លួន និងថា វិធីសាស្ត្រក្នុងការការពារខ្លួន អាចលេចចេញជារូបរាងច្បាស់លាស់ នៅពេលដែលសវនាការបន្តដំណើរទៅមុខ ឬដោយសារភាពសំខាន់ទៅលើរយៈពេលនៃការផ្តន្ទាទោសដែលត្រូវប្រឈមមុខនោះ ត្រូវបានថយចុះ នៅពេលអំឡុងពេលនៃការឃុំខ្លួនបណ្តោះអាសន្ននឹងត្រូវបានចាត់ទុកថា ជាផ្នែកមួយនៃការផ្តន្ទាទោស[69]។ អាស្រ័យហេតុនេះ ផ្ទុយទៅវិញនោះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង តម្រូវឲ្យមានការពន្យល់បកស្រាយដែលមានសំអាងហេតុ។ តាមទស្សនៈរបស់អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់សម្រាប់ការបន្តឃុំខ្លួន ខៀវ សំផន នោះឡើយ។

34. ក្នុងពេលពិនិត្យមើលលើលក្ខខណ្ឌសម្រាប់ការឃុំខ្លួន ខៀវ សំផន ក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូង គប្បីធ្វើការពិចារណាដល់ការទាញយករយៈពេលពីរឆ្នាំនៃការជំនុំជម្រះ និងបណ្តឹង ដែលនៅចំពោះមុខខ្លួន។ យោងតាមបទដ្ឋានដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវតែបញ្ចប់ការឃុំខ្លួន ក្នុងករណីដែលមានការវិវឌ្ឍន៍នៅក្នុងការជំនុំជម្រះ ដែលបង្ហាញថា ភស្តុតាងដែលបង្កើតបានជាសំអាងហេតុ ដែលអាចឱ្យជាជឿបានថា ជនរូបនេះត្រូវតែស្ថិតក្នុងមន្ទីរឃុំឃាំង បានប្រព្រឹត្តិឧក្រិដ្ឋជាក់លាក់មួយ ឬច្រើន ទទួលរងការជំទាស់ ថមថយទម្ងន់ ឬត្រូវបានបង្ហាញថាមិនពាក់ព័ន្ធ ដែលធ្វើឲ្យគ្មានភាពចាំបាច់ក្នុងការឃុំខ្លួនបន្តទៀត។ ការប្រែប្រួលកាលៈទេសៈ អាចបណ្តាលមកពីសមាសធាតុណាមួយនៃការប្រែប្រួលថ្មី នៅក្នុងភស្តុតាង ដូចជាអង្គហេតុដែលទើបរកឃើញ

---

ដោយកត់សម្គាល់ថា ខ្លួនមិនអាចស្រាយបំភ្លឺបង្ហាញថាតើការដោះលែងអ្នកដាក់ពាក្យសុំ "អាចរាំងដល់ដំណើរការពិនិត្យទាំងស្រុង គ្រប់ជ្រុងជ្រោយ និងដោយសត្យានុម័តទៅលើរឿងក្តី ដោយរបៀបណានោះទេ"។ សូមបន្ថែមពី ECHR ទៀត។

[69] *សូមមើល*, *e.g*, តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR), *Neumeister ទល់នឹង Austria*, សាលក្រម, ថ្ងៃទី ២៧ ខែ ១៩៦៨, សំណើសុំលេខ 1936/63, កថាខណ្ឌ ១០ ("គ្រោះថ្នាក់ក្នុងការរត់គេចខ្លួន មិនអាចត្រូវបានគេវាយតម្លៃ ដោយផ្អែកតែទៅលើ [ភាពធ្ងន់ធ្ងរនៃបទចោទ]។កត្តាដទៃទៀត ជាពិសេសទាក់ទងទៅនឹងចរិតនៃបុគ្គលដែលជាប់ពាក់ព័ន្ធ សីលធម៌របស់គាត់ ផ្ទះសំបែងរបស់គាត់ ការងាររបស់គាត់ ទ្រព្យសម្បត្តិរបស់គាត់ ទំនាក់ទំនងគ្រួសាររបស់គាត់ និងគ្រប់ការទំនាក់ទំនងជាមួយនឹងប្រទេស ដែលខ្លួនត្រូវចោទប្រកាន់ក្នុងប្រទេសនោះ អាចបង្ហាញថាមានហានិភ័យក្នុងការរត់គេចខ្លួន ឬធ្វើឱ្យមើលទៅជារឿងតូចតាច ដែលពុំអាចយកមកឃុំខ្លួន ដោយរង់ចាំការជំនុំជម្រះឡើយ។ គប្បីចងចាំថា ហានិភ័យនៃការរត់គេចខ្លួនបានថយចុះ នៅពេលដែលពេលវេលាចំណាយលើការឃុំខ្លួន បានកន្លងផុតទៅ ពីព្រោះដោយជឿថា រយៈពេលនៃការឃុំខ្លួននេះ នឹងត្រូវបានរាប់បញ្ចូលទៅក្នុងរយៈពេលជាប់ព័ន្ធនាគារ ដែលបុគ្គលជាប់ពាក់ព័ន្ធនេះ អាចរំពឹងទុកថាមាន ប្រសិនបើត្រូវបានផ្តន្ទាទោសមែននោះ នេះទំនងជាធ្វើឱ្យការរំពឹងទុកហាក់បីដូចជាពុំសូវអស្ចារ្យសំរាប់គាត់ ហើយកាត់បន្ថយការប៉ុនប៉ងរត់គេចខ្លួន"។ (សេចក្តីបញ្ជាក់បន្ថែម))។ *សូមមើលផងដែរ រឿងក្តី I.A. ទល់នឹង France*, សាលក្រម, ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៨, សំណើសុំលេខ 28213/95, កថាខណ្ឌ ១០៥ ។

ថ្មី, មធ្យោបាយថ្មីនៃភស្តុតាង, ឬក៏សមាសធាតុដែលទើបតែបង្ហាញថ្មីណាមួយដែលអាចជម្រុញដោយសម ហេតុផលដល់ការវាយតម្លៃឡើងវិញទៅលើភស្តុតាងដែលប្រមូលបានកន្លងមក។ ដូចគ្នានេះ បន្ទាប់ពីឆ្លង ផុតអំឡុងពេលវេលាមួយទៅ តុលាការចាំបាច់ត្រូវតែបង្ហាញថាតើមូលដ្ឋានដទៃទៀត ដែលបានដកស្រង់មក នៅតែអាចផ្តល់ជាយុត្តិកម្មសម្រាប់ការដកហូតសិទ្ធិសេរីភាពបន្តទៀតបានដែរឬយ៉ាងណា[70]។

35. លើសពីនេះទៅទៀត វាចាំបាច់ត្រូវតែមានទំនាក់ទំនងរវាងបុគ្គលដែលត្រូវបានគេដកហូតសិទ្ធិសេរី ភាព និងព្រឹត្តិការណ៍ដែលបង្កើតជាបទល្មើស ហើយថែមទាំងមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការសន្និដ្ឋានថា ព្រឹត្តិការណ៍ទាំងនោះ ស្ថិតក្នុងវិសាលភាពនៃបទល្មើសដែលបានចោទប្រកាន់។ ក្នុងការអនុវត្តជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា វាអាចមានការលំបាកសម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើការ វាយតម្លៃមួយបែបនោះ មុនកិច្ចដំណើរការនីតិវិធីសួរដេញដោលលើភស្តុតាងត្រូវបានបញ្ចប់ទៅនោះ[71]។ ការផ្លាស់ប្តូរកាលៈទេសៈដែលធ្វើឲ្យប៉ះពាល់ដល់ភាពចាំបាច់សម្រាប់ការឃុំខ្លួនបន្តទៅទៀត អាចតម្រូវឲ្យ មានលក្ខណៈជាក់ស្តែង[72] និងចាំបាច់គ្រប់គ្រាន់ដើម្បីទូទាត់ចំពោះភាពធ្ងន់ធ្ងរនៃភស្តុតាងដាក់បន្ទុក និងមាន លក្ខណៈរឹងមាំ[73]។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង ពុំបានធ្វើការកែប្រែ ចំពោះវិសាលភាពនេះឡើយ។

36. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា នៅក្នុងកាលៈទេសៈនៃសំណុំរឿង ០០២ កត្តាដែល ជំរុញឲ្យ ខៀវ សំផន រត់គេចខ្លួននាពេលនេះ អាចធ្ងន់ធ្ងរជាងពីមុនទៅទៀត។ រហូតមកទល់នឹងពេលថ្មីៗ នេះ ការមិនមានការពិចារណាឲ្យបានរឹងមាំអំពីវិសាលភាពនៃដំណាក់កាល សម្រាប់បុគ្គលម្នាក់ៗនៅក្នុង សំណុំរឿង ០០២ នោះកិច្ចដំណើរការនីតិវិធីមិនបានផ្តល់ការរំពឹងទុកឲ្យបានច្បាស់លាស់នៃការឈានដល់ ការចេញសាលក្រមនោះឡើយ។ លើសពីនេះទៅទៀត កិច្ចដំណើរការនីតិវិធីដែលត្រូវបានសម្រេចពន្យារ

---

[70] *សូមមើល* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) *រឿងក្តី* Letellier *ទល់នឹង* ប្រទេសបារាំង France សាលក្រម ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩១ កម្រងឯកសារ ក លេខ ២០៧ ទំព័រ១៨ ជើងទំព័រ ៣៥។

[71] ភាពនីយភាពនៃពិរុទ្ធភាពអាចខុសៗគ្នាអាស្រ័យលើបំណែកនីមួយៗនៃភស្តុតាងដែលបានបង្ហាញជូន។ ជាលទ្ធផល កម្រិតនៃ ការបង្ហាញភស្តុតាងនៅក្នុងសវនាការ។

[72] អាចនិយាយម្យ៉ាងទៀតបានថា ធាតុផ្សំថ្មីត្រូវតែមានភាពទាក់ទាញយ៉ាងខ្លាំង ដើម្បីអនុញ្ញាតឲ្យមានការវិនិច្ឆ័យបែបនោះទៅ បាន ទោះបីជាមុនពិភាក្សាសម្រេចចុងក្រោយក៏ដោយ។

[73] ម្យ៉ាងវិញទៀត ត្រូវតែបញ្ជាក់ថា ភស្តុតាងដែលមិនទាន់ទទួលបាននៅឡើយ *ជាគោលការណ៍* អាចត្រូវបានចាត់ទុកថាមិនមាន ភាពពាក់ព័ន្ធ ឬមិនមានសារៈសំខាន់ចំពោះលទ្ធផលទូទៅនៃកិច្ចដំណើរការនីតិវិធីនោះឡើយ។

ពេល ដោយសារតែបញ្ហាសុខភាពរបស់ជនជាប់ចោទនោះ[74] ត្រូវបានគេកត់សម្គាល់ដោយមានការចោទប្រកាន់ថា មានការជ្រៀតជ្រែកខាងនយោបាយ[75] និងត្រូវបានគេរាយការណ៍ថា មានភាពរុំរ៉ៃមិនច្បាស់លាស់ ដោយសារតែកង្វះថវិកា[76]។ សរុបមកលក្ខខណ្ឌទាំងនេះអាចធ្វើឲ្យ ខៀវ សំផន មានចំណាប់អារម្មណ៍ទៅលើលទ្ធភាពពិតប្រាកដមួយថា នឹងមិនមានសាលក្រមសម្រាប់សំណុំរឿង ០០២ ឬថា សាលក្រមនឹងមិនអាចចេញបាននៅក្នុងអំឡុងពេលដែលគាត់មានជីវិតនោះឡើយ។

37. ការបំបែកកិច្ចដំណើរការនីតិវិធីក្នុសំណុំរឿង ០០២ វិសាលភាពកំណត់ពីវិសាលភាពនៃសំណុំរឿង ០០២/០១ និងការឈានទៅរកការបញ្ចប់នៃសំណុំរឿងនេះ នាំឲ្យមានការរំពឹងទុកច្បាស់លាស់មួយក្នុងការចេញសាលក្រម។ ដោយពិចារណាទៅលើអាយុកាន់តែចាស់របស់ ខៀវ សំផន និងដោយយោងទៅលើភាពធ្ងន់ធ្ងរនៃបទចោទចំពោះគាត់ ការផ្តន្ទាទោស និងការកាត់ទោសឱ្យជាប់ពន្ធនាគារណាមួយ ជាក់ស្តែងអាចស្មើនឹងទោសអស់មួយជីវិត។ ហេតុដូច្នេះ ការគិតបញ្ចូលនូវពេលវេលាដែលបានចំណាយនៅក្នុងការជាប់ឃុំឃាំង ធៀបនឹងការផ្តន្ទាទោសបែបសម្មតិកម្ម ធ្វើឱ្យគាត់មានភាពធូរស្រាលជាង។ ជម្រើសរវាងការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត *តាមព្រឹត្តិហេតុ* និងហានិភ័យនៃការរត់គេចខ្លួន អាចមិនបណ្តាលឲ្យមានភាពខុសគ្នាខ្លាំងនោះទេ ទាក់ទងទៅនឹងកម្រិត និងរយៈពេលនៃការរងទុក្ខព្រួយដែលកើតមានកន្លងម។ លើសពីនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការគំរាមកំហែងដែលនឹងកើតមានចំពោះកិច្ចដំណើរការនីតិវិធីបន្តទៅទៀត នឹងបណ្តាលឲ្យមានហានិភ័យនៃការរត់គេចខ្លួនកាន់ខ្លាំងឡើង[77]។ ទោះបីជាសំណុំរឿង ០០២/០២ មិនទាន់បានចាប់ផ្តើមក៏ដោយ ក៏បទចោទ

---

[74] *សូមមើល ឧទាហរណ៍,* សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូលលើដីកាបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៤៩។

[75] *សូមមើល ឧ.* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណើសុំឱ្យធ្វើចំណាត់ជាបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ថ្ងៃទិ ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E176/2/1/4, កថាខណ្ឌ ៦ ដល់ ៧។

[76] *សូមមើល ឧ.* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា "ប្រឆាំងនឹងការបដិសេធចោលដោយពុំចាត់ការលើសំណើសុំចំណាត់ការបន្ទាន់ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង", ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារលេខ E189/2/3, កថាខណ្ឌ ៥ ជើងទំព័រ ១៣។

[77] *សូមមើល ឧ.* គណៈកម្មការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("EComHR"), *រឿងក្តី X. ទល់នឹង Switzerland*, សេចក្តីសម្រេច ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៨០, សំណើសុំលេខ 8788/79, កថាខណ្ឌ ២ ("អាជ្ញាធរស្វីស មានសិទ្ធិធ្វើការពិនិត្យ ដោយសារជាកត្តាជាក់ស្តែងមួយ ក្នុងការវាយតម្លៃលើហានិភ័យនៃការរត់គេចខ្លួន លើការគំរាមកំហែងនៃបទចោទដែល បានធ្វើការចោទប្រកាន់លើម្ចាស់ប្តឹងសាទុក្ខ")។

ប្រឆាំងមកលើ ខៀវ សំផន ពុំទាន់បានដោះស្រាយនៅឡើយទេ ហើយអង្គជំនុំជម្រះតុលាការកំពូល បានទទួចឲ្យបើសវនាការលើសំណុំរឿង ០០២/០២ នេះឲ្យបានឆាប់រហ័ស ហើយរំពឹងថានឹងមានលទ្ធផល ជាក់ស្តែង[78]។

38. មេធាវីការពារក្តីលើកឡើងថា ខៀវ សំផន តែងតែបានត្រៀមខ្លួនជានិច្ចដើម្បីឆ្លើយទៅនឹងការចោទប្រកាន់ណាមួយមកលើរូបគាត់នៅក្នុងតុលាការ និងថា អាកប្បកិរិយារបស់គាត់ ដូចដែលបានស្តែងឡើងតាមរយៈសេចក្តីថ្លែងការណ៍ជាសាធារណៈ និងកិច្ចសម្ភាសន៍របស់គាត់ ព្រមទាំងសៀវភៅដែលគាត់និពន្ធ និងវត្តមានជាទៀតទាត់របស់គាត់នៅក្នុងសវនាការ ទោះជាគាត់មានវ័យចាស់ជរាក្តី បង្ហាញថា គាត់គោរពចំពោះយុត្តិធម៌ និងនីតិរដ្ឋ[79]។ មេធាវីការពារក្តីអះអាងថា អង្គហេតុទាំងនេះគាំទ្រដល់ការជឿទុកចិត្តថា គាត់មិនបង្កឲ្យមានហានិភ័យនៃការរត់គេចខ្លួននោះទេ[80]។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ខៀវ សំផន បានធ្វើសេចក្តីថ្លែងការណ៍ដែលបង្ហាញថាគាត់មិនមានឆន្ទៈចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនោះទេ ហើយជាការពិត គាត់បានធ្វើការជំទាស់តវ៉ាទៅលើធម្មានុរូបភាពនៃកិច្ចដំណើរការនីតិវិធីទាំងនេះ[81]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញបន្ថែមទៀតថា នៅចុងបញ្ចប់នៃសវនាការដេញដោលទៅលើភស្តុតាង ខៀវ សំផន បានបដិសេធមិនព្រមអង្គុយនៅមុខឈើរាងក្រចកសេះ ឬមិនឆ្លើយទៅនឹងសំណួរណាមួយឡើយ ដោយប្រកាសថា គាត់ "លែងមានជំនឿលើតុលាការនេះទៀតហើយ" ដោយសារមូលហេតុនៃការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់គាត់[82]។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល ការច្រានចោលច្បាស់ក្រឡែតបែបនេះរបស់

---

[78] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ប្រឆាំងនឹងសេចក្តីសម្រេចទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីដីកាបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២–សេចក្តីសង្ខេបនៃសំអាងហេតុ, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣, ឯកសារលេខ E284/4/7 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើដីកាបំបែកកិច្ចដំណើរការនីតិវិធី")។ សំអាងពេញលេញសម្រាប់សេចក្តីសម្រេចនេះ នឹងត្រូវចេញក្នុងពេលឆាប់ៗខាងមុខ។

[79] បណ្តឹងសាទុក្ខ ពីកថាខណ្ឌ ២៧ ដល់ ២៨។

[80] បណ្តឹងសាទុក្ខ កថាខណ្ឌ ២៨។

[81] ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារលេខ E1/180.1, ពីទំព័រ ៨០ ដល់ ៨២ និង *ឯកសារយោងត្រូវបានដកស្រង់នៅទីនោះ*។

[82] ប្រតិចារឹក ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៣, ឯកសារលេខ E1/220.1, ទំព័រ ៣០។ *សូមមើលផងដែរ* លិខិតផ្ញើជូននិពន្ធនាយក ភ្នំពេញប៉ុស្ត៍, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣, មានក្នុងវេបសាយ< http://www.phnompenhpost.com/analysis-and-op-ed/khieu-samphan-forced-remain-silent>។

អ.វ.ត.ក ពុំបានផ្តល់នូវទំនុកចិត្តថា ខៀវ សំផន នឹងអនុវត្តតាមដីកាកោះហៅឱ្យត្រឡប់មកវិញប្រកបដោយឆន្ទៈនោះទេ ប្រសិនបើគាត់ត្រូវបានដោះលែងមែននោះ។

39. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនៅតែយល់ឃើញថា មូលដ្ឋានគតិយុត្តិសម្រាប់ការបន្តឃុំខ្លួន ខៀវ សំផន ដោយអនុលោមតាមវិធាន ៦៣(៣)(ខ)(iii) នៅតែមានសុពលភាពដដែល ហើយសម្អាងហេតុទាំងនេះមានការពាក់ព័ន្ធតិចតួចទៅនឹងហានិភ័យទូទៅនៃការរត់គេចខ្លួនរបស់គាត់ ប្រឈមមុខទៅនឹងភាពធ្ងន់ធ្ងរនៃទណ្ឌកម្មជាចម្បង ប៉ុន្តែ វាមានការពាក់ព័ន្ធច្រើនជាមួយនឹងហានិភ័យនៃការមិនមានវត្តមានរបស់គាត់នៅក្នុងសវនាការ[83]។ អង្គជំនុំជម្រះតុលាការកំពូលមិនយល់ស្របទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តីឡើយដែលថា វ័យចាស់ជរារបស់ ខៀវ សំផន ស្ថានភាពហិរញ្ញវត្ថុ ឬការមិនមានលិខិតឆ្លងដែន រារាំងគាត់ក្នុងការលាក់ខ្លួនបាន ឬរារាំងគាត់មិនឱ្យធ្វើមិនដឹងមិនឮចំពោះដីកាកោះហៅ ប្រសិនបើគាត់មានបំណងធ្វើបែបនេះមែននោះ។ ទាក់ទងនឹងការសុំឱ្យដោះលែងដោយមានលក្ខខណ្ឌ និងការធានាដែលបានលើកឡើងដោយ ខៀវ សំផន[84] អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងថា ការធានាទាំងនេះមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីធានាដល់វត្តមានរបស់ ខៀវ សំផន នោះទេ[85]។ ការធានាត្រូវតែទទួលបានការវាយតម្លៃ "ជាគោលការណ៍ដោយការសម្អាងទៅលើ [ជនជាប់ចោទ] ទ្រព្យសម្បត្តិរបស់ជនជាប់ចោទ និងទំនាក់ទំនងរបស់ជនជាប់ចោទជាមួយបុគ្គលដែលជាអ្នកផ្តល់សន្តិសុខដល់រូបគាត់"[86]។ ការធានាដែលបានលើកឡើងនេះ កើតមានជាចម្បងដោយការធានាផ្ទាល់របស់ ខៀវ សំផន និងសមាជិកគ្រួសាររបស់គាត់ ដែលគាត់ទំនងជាចែករំលែកផលប្រយោជន៍រួមជាមួយអ្នកទាំងនោះ។ ខៀវ សំផន មិនបានលើកឡើងពីផ្នែកហិរញ្ញវត្ថុ ឬទ្រព្យផ្សេងទៀតដែលអាចធានាដល់ "ការរារាំងឱ្យបានគ្រប់គ្រាន់ដើម្បីកម្ចាត់ចោលគោលបំណងណាមួយរបស់គាត់ក្នុងការរត់គេចខ្លួន"[87]។

---

[83] សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីសំណើសុំឱ្យដោះលែងជាបន្ទាន់ កថាខណ្ឌ ៤៥។

[84] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣០ ដល់ ៤០។ សំណើសុំ ពីកថាខណ្ឌ ៥០ ដល់ ៦២។

[85] សេចក្តីសម្រេចរងការជំទាស់ កថាខណ្ឌ ២១។

[86] តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR), *រឿងក្តី Neumeister ទល់នឹង Austria*, សាលក្រម, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៦៨, សំណើសុំលេខ 1936/63, កថាខណ្ឌ ១៤។

[87] តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR), *រឿងក្តី **Neumeister** ទល់នឹង ប្រទេសអូស្ត្រាលី* សាលក្រម, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៦៨, សំណើសុំលេខ 1936/63, កថាខណ្ឌ ១៤។ *សូមមើល* គណៈកម្មការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (EComHR), *រឿងក្តី Bonnechaux ទល់នឹង Switzerland*, សំណើសុំលេខ 8224/78, របាយការណ៍ របស់គណៈកម្មការ (Strasbourg: 1980), កថាខណ្ឌ ៧៣។

40. ទោះជាយ៉ាងណាក៏ដោយ ការពិចារណា និងសេចក្តីសន្និដ្ឋាននានា ដែលបានលើកឡើងខាងលើ មានសុពលភាពទៅបានលុះណាតែ តម្រូវការធានាចំពោះវត្តមានរបស់ ខៀវ សំផន នៅពេលសវនាការ បន្តកើតមានជារៀងរហូត ដើម្បីធានានូវកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័ស។ អាស្រ័យហេតុនេះ ការពិចារណា និងសេចក្តីសន្និដ្ឋានខាងលើ ជាគោលការណ៍ ជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ ដែលក្នុងនោះ សារណាបិទកិច្ចពិភាក្សាដេញដោលកំពុងត្រូវបានរៀបចំឡើង ហើយបច្ចុប្បន្ននេះ ត្រូវបានកំណត់ធ្វើនៅចន្លោះថ្ងៃទី ១៦ ដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣[88]។ ហេតុដូច្នេះ តម្រូវការដើម្បីធានាចំពោះវត្តមានរបស់ ខៀវ សំផន នៅក្នុងពេលសវនាការ អាចនឹងចុះថយ បើទោះជាមិនផុតរលត់ទាំងស្រុងដរាបណាតុលាការមិនមានសកម្មភាព ដូចជា នៅក្នុងអំឡុងពេលធ្វើសេចក្តីព្រាងសាលក្រមក្នុងសំណុំរឿង ០០២/០១ ហើយទាំងនេះដោយរួមផ្សំនឹងការពន្យារពេលដោយមិនមានមូលហេតុ ក្នុងការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីទៅលើសំណុំរឿង ០០២/០២ ទៀត អាចបង្កើតបានជាទឡ្ហីករណ៍សម្រាប់ការជំនួសការឃុំខ្លួន ដោយវិធានការមិនសូវតឹងរ៉ឹងពេក ដូចជាការត្រួតពិនិត្យតាមផ្លូវតុលាការ ជាដើម។

41. ប៉ុន្តែ នាពេលនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការដោះលែង ខៀវ សំផន ជាបន្ទាន់ដោយមានលក្ខខណ្ឌមិនត្រូវបានអនុញ្ញាតនោះទេ។ ដោយយោងទៅលើមូលហេតុខាងលើនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មេធាវីការពារក្តីមិនបង្ហាញឲ្យបានគ្រប់គ្រាន់ថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការមិនបានផ្តល់សម្អាងហេតុឲ្យបានគ្រប់គ្រាន់សម្រាប់ការបន្តឃុំខ្លួន ខៀវ សំផន ធ្វើឲ្យសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអស់សុពលភាពនោះទេ។ ហេតុដូច្នេះ ទឡ្ហីករណ៍ទាំងនេះ ត្រូវបានបដិសេធចោល។

## ខ. ការចោទប្រកាន់ថា ការឃុំខ្លួនបណ្តោះអាសន្នលើសពេលកំណត់

42. នៅក្នុងការបដិសេធសំណើសុំឲ្យដោះលែង ខៀវ សំផន ជាបន្ទាន់ដោយមានលក្ខខណ្ឌ និងការបង្គាប់ឲ្យបន្តឃុំខ្លួន ខៀវ សំផន ជាបណ្តោះអាសន្នតទៅទៀតនោះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សម្អាងហេតុបន្ថែមទៀតថា៖

[88] អនុស្សរណៈរបស់ចៅក្រម និល នុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ចំណងជើងថា "កាលបរិច្ឆេទដែលត្រូវបានកែសម្រួលសម្រាប់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ឯកសារលេខ (E295/1, E295/1/2, E295/1/3, E295/2 and E295/3)", E295/4, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣។

ការបន្តឃុំខ្លួន ខៀវ សំផន មិនមែនមិនសមស្របគ្រប់កាលៈទេសៈទាំងអស់នៃរឿងក្តីនោះទេ។ នៅក្នុងសំណុំរឿងនានាដែលមានភាពស្មុគស្មាញប្រហាក់ប្រហែលទៅនឹងសំណុំរឿង ០០២ ការឃុំខ្លួនរយៈពេលប្រាំ (៥) ឆ្នាំ ឬយូរជាងនេះ ត្រូវបានចាត់ទុកថាជាការសមស្រប នៅគ្រប់កាលៈទេសៈទាំងអស់។ នៅពេលដែលគ្រប់កាលៈទេសៈទាំងអស់ត្រូវបានពិចារណា រួមទាំងការយល់ឃើញថា "ការជំនុំជម្រះសំណុំរឿង ០០២ "គឺជាកិច្ចការដែលត្រូវត្រៀមរៀបចំយ៉ាងធំធេង និងមានភស្តុតាងយ៉ាងច្រើន" ការជំនុំជម្រះបានដំណើរការទៅមុខយ៉ាងឆាប់រហ័ស តាមដែលអាចធ្វើទៅបាន។ ទោះជាក្នុងករណីណាក៏ដោយ និងដោយយល់ឃើញថា សំណុំរឿង ០០២/០១ កំពុងឈានទៅរកដំណាក់កាលបញ្ចប់របស់វា អង្គជំនុំជម្រះមិនទទួលយក [...] របស់មេធាវីការពារក្តី ខៀវ សំផន ដែលថា ជនជាប់ចោទមិនអាចប្រមើលឃើញ ឬមានភាពច្បាស់លាស់ទាក់ទងទៅនឹងថេរវេលានៃការជំនុំជម្រះនេះឡើយ។ អង្គជំនុំជម្រះយល់ឃើញថា វ័យចាស់ជរារបស់ [ខៀវ សំផន] មិនមែនធ្វើឱ្យការឃុំខ្លួនគាត់មិនសមស្របនោះទេ។ កត្តាទាំងឡាយដែលផ្តល់ភាពសមហេតុផលដល់ការបន្តឃុំខ្លួនគាត់ មានភាពលើសលប់លើកត្តាផ្ទាល់ខ្លួនរបស់ជនជាប់ចោទ នៅពេលដែលអង្គជំនុំជម្រះធ្វើការពិចារណាអំពីបទដ្ឋាននៃការយកចិត្តទុកដាក់ដែលត្រូវបានផ្តល់ទៅឱ្យ [ខៀវ សំផន] និងការគោរពសិទ្ធិរបស់ជនជាប់ចោទដែលបានផ្តល់ឱ្យដោយមន្ទីរឃុំឃាំងនៃ អ.វ.ត.ក[89]។

43. មេធាវីការពារក្តីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយការខកខានមិនបានពិចារណាទៅលើអំឡុងពេលស៊ើបអង្កេតរបស់តុលាការ នៅក្នុងការវិភាគរបស់ខ្លួន ថាតើរយៈពេលនៃការឃុំខ្លួន ខៀវ សំផន បណ្តោះអាសន្នសមហេតុសមផលដែរឬយ៉ាងណានោះ[90]។ មេធាវីការពារក្តីអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយការប្រៀបធៀបករណីរបស់ ខៀវ សំផន ទៅនឹងរឿងក្តីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ដែលកិច្ចដំណើរការនីតិវិធីសួរដេញដោលជាចាំបាច់តាមច្បាប់ប្រព័ន្ធអង់គ្លូសាក់សុង មានរយៈពេលយ៉ាងយូរជាងកិច្ចដំណើរការនីតិវិធី ដែលត្រូវបានដំណើរការដោយកិច្ចស៊ើបអង្កេតរបស់តុលាការ ដូចជាកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក នេះឆ្ងាយណាស់[91]។ លើសពីនេះទៅទៀត មេធាវីការពារក្តីជំទាស់តវ៉ាថា ក្រៅពីសំណុំរឿង ០០២/០១ ដែលកំពុងឈានទៅរកការបញ្ចប់ នៅតែមានការខ្វះការប៉ាន់ប្រមាណតាមផ្លូវតុលាការ និងភាពជាក់លាក់អំពីរយៈពេលនៃ

---

[89] សេចក្តីសម្រេចរងការជំទាស់ កថាខណ្ឌ ២៣ (សេចក្តីដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[90] បណ្តឹងសាទុក្ខ ពីកថាខណ្ឌ ៤៩-៥៥។

[91] បណ្តឹងសាទុក្ខ ពីកថាខណ្ឌ ៥៦-៥៧។

សវនាការជំនុំជម្រះសំណុំរឿង ០០២ ទាំងមូលតែម្តង[92]។ មេធាវីការពារក្តីជំទាស់ថា ក្រៅតែពីការពិចារណាទៅលើវ័យចាស់ជរារបស់ ខៀវ សំផន នៅក្នុងការពិនិត្យទៅលើភាពសមស្របនៃការបន្តឃុំខ្លួនគាត់ អង្គជំនុំជម្រះសាលាដំបូងគួរតែបានពិចារណាបញ្ហានេះរួមជាមួយនឹងកត្តាពាក់ព័ន្ធដទៃទៀត មានន័យថា ការពន្យារពេល ការមិនអាចព្យាករបាន និងការមិនមានភាពច្បាស់លាស់របស់តុលាការ ដែលកត្តាទាំងអស់នេះនាំឲ្យមានសេចក្តីសន្និដ្ឋានដែលសមហេតុផលតែមួយគត់ គឺការឃុំខ្លួនបណ្តោះអាសន្នរបស់គាត់ មានរយៈពេលយូរហួសហេតុពេក[93]។

44. សហព្រះរាជអាជ្ញាឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងយកចិត្តទុកដាក់លើទាំងរយៈពេលឃុំខ្លួននៅក្នុងដំណាក់កាលស៊ើបអង្កេត និងទាំងរយៈពេលឃុំខ្លួននៅក្នុងដំណាក់កាលជំនុំជម្រះនៅក្នុងការវិភាគរបស់ខ្លួន[94] ដោយបានធ្វើការប្រៀបធៀបយ៉ាងត្រឹមត្រូវរវាងសំណុំរឿង ០០២ ជាមួយនឹងរឿងក្តីទាំងឡាយ ដែលមានលក្ខណៈស្មុគស្មាញស្រដៀងគ្នានៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា[95] និងដោយបានពិចារណាយ៉ាងត្រឹមត្រូវលើវ័យចំណាស់របស់ជនជាប់ចោទ រួមជាមួយនឹងកត្តាពាក់ព័ន្ធទាំងអស់ផ្សេងទៀតដែលផ្តល់យុត្តិកម្មលើការបន្តឃុំខ្លួនជនជាប់ចោទ[96]។ សហព្រះរាជអាជ្ញាអះអាងថា ក្រុមមេធាវីការពារក្តីខកខានមិនបានផ្តល់មូលដ្ឋានសម្រាប់ការអះអាងរបស់ខ្លួនថា ការព្យាករ និងភាពជាក់ច្បាស់របស់តុលាការ គឺជាកត្តាពាក់ព័ន្ធ ហើយទោះក្នុងករណីណាក៏ដោយ ភាពអាចប្រមើលមើលបានលើការបញ្ចប់ការជំនុំជម្រះ និងការចេញសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ពុំអាចយកមកជំទាស់តវ៉ាយ៉ាងដាច់អហង្កាបានទៀតឡើយ[97]។

45. ផ្ទុយនឹងការអះអាងរបស់ក្រុមមេធាវីការពារក្តីថា រយៈពេលនៃកិច្ចស៊ើបអង្កេតរបស់តុលាការពុំត្រូវបានយកមកពិចារណានៅក្នុងការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់រយៈពេលឃុំខ្លួនមុនដំណាក់កាលជំនុំជម្រះយ៉ាងយកចិត្តទុកដាក់ដោយគិតរាប់ចាប់ "ពីពេលជននោះត្រូវបានឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងរហូតដល់ពេលមាន

---

[92] បណ្តឹងសាទុក្ខ ពីកថាខណ្ឌ ៥៨-៧០។

[93] បណ្តឹងសាទុក្ខ ពីកថាខណ្ឌ ៧១-៧៥។

[94] ចម្លើយតប កថាខណ្ឌ ៣៥ ៣៧-៣៨។ *សូមមើលផងដែរ* ចម្លើយតប កថាខណ្ឌ ៣៩។

[95] ចម្លើយតប កថាខណ្ឌ ៣៦។

[96] ចម្លើយតប កថាខណ្ឌ ៤១។

[97] ចម្លើយតប កថាខណ្ឌ ៤០។

សាលក្រមរបស់តុលាការជាន់ដំបូង"[98] និងបានគណនាយ៉ាងត្រឹមត្រូវដោយគិតចាប់ផ្តើមពីថ្ងៃដែលជនជាប់ចោទត្រូវបានឃុំខ្លួនតាមអំណាចដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត[99]។ ចំពោះការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថា ខ្លួននឹងមិនពិចារណាលើអត្ថបទដកស្រង់ចេញពីក្នុងសៀវភៅរបស់ចៅក្រម LEMONDE នៅក្នុងការវិភាគរបស់ខ្លួន ពុំបានធ្វើឱ្យបាត់បង់នូវភាពសមហេតុផលនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ តុលាការស្តីពីសិទ្ធិមនុស្ស នៅពេលសម្រេចថាតើ មានការរំលោភលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះ ក្នុងពេលសមស្រប ដែរ ឬយ៉ាងណា និងក្នុងការបញ្ជាក់ច្បាស់ថាតើស្ថាប័នជាតិដែលមានសមត្ថកិច្ច បានបង្ហាញនូវ"ការយកចិត្តទុកដាក់យ៉ាងពិសេស" នៅក្នុងកិច្ចដំណើរការនីតិវិធី ដែរ ឬយ៉ាងណា[100] តុលាការនេះបានធ្វើការពិចារណា បន្ថែមលើអំឡុងពេលនៃការឃុំខ្លួន ថាតើស្ថាប័នទាំងនេះមានការអូសបន្លាយ "អសកម្មភាព" ឬ"គ្មានសកម្មភាព"[101]ដែរ ឬយ៉ាងណា។ ក្រុមមេធាវី

---

[98] សេចក្តីសម្រេចដែលត្រូវបានជំទាស់ លេខយោងជើងទំព័រ ៤៧។

[99] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២។

[100] តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR), *រឿងក្តី Letellier ទល់នឹង France*, សាលក្រម, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩១, សំណើសុំលេខ 12369/86, កថាខណ្ឌ ៣៥; *រឿងក្តី Idalov ទល់នឹង Russia*, សាលក្រម, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២, សំណើសុំលេខ ១៤០ ("អាទិភាពនៃភាពមន្ទិលសង្ស័យសមហេតុផល ដែលបុគ្គលដែលត្រូវបានចាប់ខ្លួននោះ បានប្រព្រឹត្តបទល្មើស គឺជាលក្ខខណ្ឌសម្រាប់ភាពស្របច្បាប់នៃការបន្តការឃុំខ្លួន។ ប៉ុន្តែ បន្ទាប់ពីពេលវេលាកន្លងផុតទៅ បញ្ហានេះ លែងមានលក្ខណៈគ្រប់គ្រាន់តទៅទៀតហើយ។ ក្នុងករណីបែបនេះ តុលាការត្រូវបង្ហាញថា តើ ទឡ្ហីករណ៍ដែលបានលើកឡើង ដោយស្ថាប័នមានសមត្ថកិច្ច បន្តធ្វើយុត្តិកម្មលើការដកហូតសិទ្ធិសេរីភាព ដែរ ឬយ៉ាងណា។ នៅពេលដែលទឡ្ហីករណ៍នេះ មានការ "ជាប់ពាក់ព័ន្ធ" និង "គ្រប់គ្រាន់", តុលាការ ត្រូវតែបញ្ជាក់អះអាងផងដែរ ថាតើ ស្ថាប័នជាតិដែលមានសមត្ថកិច្ច បានបង្ហាញ "ការយកចិត្តទុកដាក់ពិសេស" ក្នុងកិច្ចដំណើរការនីតិវិធី ដែរ ឬយ៉ាងណា" (សេចក្តីបញ្ជាក់បន្ថែម))។ សូមមើល, *រឿងក្តី Bykov ទល់នឹង Russia*, សាលក្រម ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩, សំណើសុំលេខ 4378/02, កថាខណ្ឌ ៦៤; *រឿងក្តី McKay ទល់នឹង United Kingdom*, សាលក្រម, ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៦, សំណើសុំលេខ 543/03, កថាខណ្ឌ ៤៤; *រឿងក្តី Kudla ទល់នឹង Poland*, សាលក្រម, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០០, សំណើសុំលេខ 30210/96, កថាខណ្ឌ ១១១; *រឿងក្តី Labita ទល់នឹង Italy*, សាលក្រម, ថ្ងៃទី ០៦ ខែ មេសា ២០០០, សំណើសុំលេខ 26772/95, កថាខណ្ឌ ១៥៣។

[101] *សូមមើល* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស("ECtHR") *រឿងក្តី Assenov និងជនផ្សេងទៀត ទល់នឹង ប្រទេសប៊ុលហ្គារី* សាលក្រម ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ ពាក្យសុំលេខ ២៤៧៦០/៩៤ កថាខណ្ឌ ១៥៧-១៥៨ ("រដ្ឋាភិបាលបានលើកឡើងថា ខ្លួនចំណាយរយៈពេលពីរ (២) ឆ្នាំដើម្បីអាចបញ្ជូនរឿងក្តីនេះមកជំនុំជម្រះពីព្រោះរឿងក្តីនេះស្មុគស្មាញ តម្រូវឱ្យមានការស៊ើបអង្កេត។ ប៉ុន្តែ តាមរយៈព័ត៌មានដែលតុលាការមាន វាបានបង្ហាញថា នៅក្នុងអំឡុងពេលមួយ (១) ឆ្នាំក្នុងរយៈពេលពីរ (២) ឆ្នាំនោះ [...] ជាក់ស្តែង គ្មានកិច្ចណាមួយត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងការស៊ើបអង្កេតឡើយ ពោលគឺ គ្មានភស្តុតាងថ្មីណាមួយត្រូវបានប្រមូលបាន ហើយលោក Assenov ត្រូវបានសួរចម្លើយតែមួយលើក [...]។ យោងតាមសាវតារនេះ តុលាការបានរកឃើញថា លោក Assenov ត្រូវបានបដិសេធមិនឱ្យទទួលបាន "ការជំនុំជម្រះក្នុងរយៈពេលសមស្របមួយ" ដោយបានរំលោភលើមាត្រា ៥ § ៣" (សេចក្តីបញ្ជាក់បន្ថែម))។ *សូមមើលផងដែរ រឿងក្តី Punzelt ទល់នឹង សាធារណៈរដ្ឋឆែក*

ការពារក្តីពុំបានសន្និដ្ឋានលើកឡើងអំពីរយៈពេលនៃអសកម្មភាព ឬគ្មានសកម្មភាពនៅក្នុងសំណុំរឿង ០០២ ឡើយ។ ផ្ទុយមកវិញ ក្រុមមេធាវីការពារក្តីបែរជាអះអាងថា សំណុំរឿង ០០១ បានទទួល "អាទិភាព" ពីសហចៅក្រមស៊ើបអង្កេតទៅវិញ[102]។ បើទោះជាសំណុំរឿង ០០១ បានទទួលអាទិភាពនៅក្នុងដំណាក់កាលណាមួយក៏ដោយ នេះពុំមែនមានន័យថា ការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២ គ្មានសកម្មភាពឡើយ។ ទោះក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អត្ថបទដែលបានដកស្រង់ ពុំទាន់គ្រប់គ្រាន់ ក្នុងការគាំទ្រនូវការអះអាងអំពីភាពខ្វះនូវការយកចិត្តទុកដាក់ឡើយ។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីខកខានមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងព្រងើយកន្តើយមិនពិចារណាលើរយៈពេលស៊ើបអង្កេត នៅក្នុងការវិភាគរបស់ខ្លួនអំពីភាពសមាមាត្រទៅនឹងរយៈពេលនៃការឃុំខ្លួន ខៀវ សំផន បណ្តោះអាសន្ន។

46. អង្គជំនុំជម្រះតុលាការកំពូលក៏បានពិចារណាលើការអះអាងរបស់ក្រុមមេធាវីការពារក្តីថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលធ្វើការប្រៀបធៀបរវាងរយៈពេលឃុំខ្លួន ខៀវ សំផន បណ្តោះអាសន្នអស់រយៈពេលជាងប្រាំ (៥) ឆ្នាំ ជាមួយនឹងរឿងក្តីស្រដៀងៗគ្នានៅក្នុងកម្រិតអន្តរជាតិ ដោយពុំបានពិចារណាត្រឹមត្រូវ។ ក្រុមមេធាវីការពារក្តីខកខានក្នុងការផ្តល់មូលដ្ឋានគាំទ្រសម្រាប់ការអះអាងរបស់ខ្លួនថា កិច្ចដំណើរការនីតិវិធីធ្វើឡើងក្រោយកិច្ចស៊ើបអង្កេត ជាធម្មតា មានរយៈពេលខ្លីជាងកិច្ចដំណើរការនីតិវិធីដែលគ្មានកិច្ចស៊ើបអង្កេត។ មេធាវីការពារក្តីក៏ពុំបានពន្យល់ថា តើភាពខុសគ្នានៅក្នុងកិច្ចដំណើរការនីតិវិធីបែបនេះ អាចប៉ះពាល់រយៈពេលឃុំខ្លួនបណ្តោះអាសន្ននៅ អ.វ.ត.ក ដែរ ឬយ៉ាងណានោះទេ។ បញ្ហាជាក់ស្តែង គឺនៅត្រង់ថា ខៀវ សំផន គឺជាផ្នែកមួយនៃរឿងក្តីដែលមានជនជាប់ចោទច្រើនរូប *ដោយក្នុងនោះ* មានការពាក់ព័ន្ធទៅនឹងបទចោទនៃបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងរយៈពេលជិតប្រាំ (៤) ឆ្នាំ ហើយរឿងក្តីបែបនេះមានលក្ខណៈស្មុគស្មាញដែលកម្រឃើញមាននៅក្នុងកម្រិតជាតិ។ ហេតុដូច្នេះ ការងាកទៅប្រៀបធៀបដោយអង្គជំនុំជម្រះសាលាដំបូងរវាងរយៈពេលឃុំខ្លួនបណ្តោះអាសន្ននៅក្នុងរឿងក្តីព្រហ្មទណ្ឌស្រដៀងគ្នានៅកម្រិតអន្តរជាតិ មានលក្ខណៈសមហេតុផលទាំងស្រុង[103] ហើយ

---

សាលក្រម ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០០ ពាក្យសុំលេខ ៣១៣១៥/៩៦ កថាខណ្ឌ ៧៨-៨២។ រឿងក្តី *Barfuss ទល់នឹង សាធារណៈរដ្ឋឆែក* សាលក្រម ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០ ពាក្យសុំលេខ ៣៥៨៤៨/៩៧ កថាខណ្ឌ ៧១ ដល់ ៧៤។

[102] សំណើបន្ថែមស្នើសុំឱ្យទទួលយកមកធ្វើជាភស្តុតាង កថាខណ្ឌ ២០។

[103] តុលាការឧក្រិដ្ឋកម្មអន្តរជាតិ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ *មិនអចិន្ត្រៃយ៍* តុលាការសិទ្ធិមនុស្សអឺរ៉ុប និងគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានយោងលើយុត្តិសាស្ត្ររបស់គ្នាទៅវិញទៅមកពាក់ព័ន្ធនឹងគោលការណ៍នានា ដូចជា ភាពសមហេតុផលនៃរយៈពេលឃុំខ្លួន។ ស្ថាប័នទាំងអស់នេះសន្និដ្ឋានថា "រយៈពេលកំណត់សមស្របឬអត់នោះអាចយកមកធ្វើការវាយតម្លៃបានក្រោយពីពិចារណាលើកាលៈទេសៈទាំងអស់នៃរឿងក្តីនីមួយៗ"។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Darko

ការសន្និដ្ឋានបែបនេះ គឺគាំទ្រដោយមូលដ្ឋានដែលក្រុមមេធាវីការពារក្តីខ្លួនឯងផ្អែកលើយុត្តិសាស្ត្រនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ *មិនអចិន្ត្រៃយ៍* ដើម្បីគាំទ្រទឡ្ហីករណ៍នានានៅក្នុងបណ្តឹងសាទុក្ខចោទប្រកាន់អំពីកំហុសនៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើរយៈពេលឃុំខ្លួន ខៀវ សំផន បណ្តោះអាសន្ន[104]។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីខកខានមិនបានបង្ហាញឱ្យឃើញនូវកំហុសណាមួយលើករណីនេះឡើយ។

47. ដូចគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូល បដិសេធការលើកឡើងរបស់មេធាវីការពារក្តីដែលអះអាងថា អង្គជំនុំជម្រះសាលាដំបូងពិចារណាតែកត្តានៃវ័យចំណាស់របស់ ខៀវ សំផន តែមួយមុខប៉ុណ្ណោះ ជាជាងការពិចារណាបញ្ចូលគ្នានូវកត្តាពាក់ព័ន្ធឯទៀត។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ជាពិសេសថា "កត្តាសមស្របនានាក្នុងការបន្តឃុំខ្លួន ខៀវ សំផន មានទម្ងន់គ្រប់គ្រាន់លើសបញ្ហាផ្ទាល់ខ្លួនទាំងអស់នេះ" ដែលក្នុងនេះសំដៅទៅលើវ័យចំណាស់របស់ជនជាប់ចោទមួយផងដែរ[105]។

48. ចំណែកឯទឡ្ហីករណ៍ពាក់ព័ន្ធនឹងការព្យាកររបស់តុលាការ និងភាពប្រាកដប្រជានៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ក្រុមមេធាវីការពារក្តីលើកត្រូវ

---

*Mrda* សំណុំរឿងលេខ IT-02-59-PT សេចក្តីសម្រេចលើសំណើរបស់ Darko Mrda ស្នើសុំឱ្យដោះលែងបណ្តោះអាសន្ន ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០០២។ *សូមមើលផងដែរ* Manfred Nowak, *កតិកាសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ: CCPR Commentary,* (ការបោះពុម្ពលើកទី ពីរ, N.P. Engel: ឆ្នាំ ២០០៥) ទំព័រ ១៧៧។ Karim Khan "មាត្រា ៦០ កិច្ចដំណើរការនីតិវិធីបឋមនៅចំពោះមុខតុលាការ" នៅក្នុងសៀវភៅរបស់អ្នកនិពន្ធនាយក Otto Triffterer (ed.), *សេចក្តីអធិប្បាយស្តីពីលក្ខន្តិកៈ ទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ–Observers' Notes, Article by Article*, (2nd ed., Beck: 2008) ទំព័រ ១១៦៧ លេខយោងជើងទំព័រ ៥៣។ David Harris, Michael O'Boyle, Edward Bates and Carla Buckley (eds.), *Harris, O'Boyle & Warbrick: ច្បាប់ស្តីពីអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស*(ការបោះពុម្ពលើកទីពីរ., OUP: ឆ្នាំ២០០៩) ទំព័រ ១៧៥។

[104] *សូមមើល* បណ្តឹងសាទុក្ខ កថាខណ្ឌ ២០-២១ និង៣៤។

[104] *សូមមើល* បណ្តឹងសាទុក្ខ កថាខណ្ឌ ២០-២១ និង៣៤។

[105] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌទី ២៣។ កត្តា"ផ្ទាល់ខ្លួន"ដទៃទៀត ដែលអង្គជំនុំជម្រះសាលាដំបូងបានយោងគឺមានបញ្ចូលសារណារបស់ក្រុមមេធាវីការពារក្តីដែលថា ខៀវ សំផន"មិនដែលស្វះស្វែងរត់គេចម្តងណាទេ និង តែងតែចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរហូត ឱ្យតែតុលាការត្រូវការគាត់" និងថា "ជាមួយគ្នាផងដែរ វាជាការមិនទំនងទាល់តែសោះ ដែលថាសុខភាពមិនល្អរបស់គាត់ នឹងរារាំងមិនឱ្យគាត់ចូលរួមក្នុងសវនាការបាន" និងថា "ពុំមាន ឬមានហានិភ័យតិចតួចណាស់ចំពោះសណ្តាប់ធ្នាប់សាធារណៈ ប្រសិនបើតុលាការដោះលែង ខៀវ សំផន ជាបណ្តោះអាសន្ន" និងថា "នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី គាត់មិនដែលជួបប្រទះនឹងការការគម្រាមកំហែងណាមួយដល់សុវត្ថិភាពរបស់គាត់នោះទេ"។ *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌទី ៨ យោងទៅពាក្យសុំ កថាខណ្ឌទី ១២ ២៦ ២៨ ៣២-៣៥ និង ៤០។

ចំណុច។ ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ថា ការបន្តការឃុំខ្លួនជនជាប់ចោទ ត្រូវមានការជាប់ពាក់ព័ន្ធទៅនឹងបទចោទជាក់លាក់ដែលតម្រូវឱ្យមានកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ក្នុងការប្រកាសអំពីភាពគ្មានសុពលភាពនៃការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយនៃសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ថា សេចក្តីសម្រេចដំបូងរបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីដំបូងនេះ គឺមិនធ្វើឱ្យប៉ះពាល់ដល់ការវាយតម្លៃឡើងវិញនៃការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ របស់អង្គជំនុំជម្រះសាលាដំបូងនោះឡើយ។ ប៉ុន្តែ ដីកាបំបែកកិច្ចដំណើរការនីតិវិធីថ្មីនេះ ត្រូវតែមានបញ្ចូលផែនការជាក់លាក់មួយ ដើម្បីធ្វើការសម្រេចសេចក្តីទៅលើបទចោទទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយ[106]។ ក្នុងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿងសាជាថ្មី អង្គជំនុំជម្រះសាលាដំបូង មិនបានអនុវត្តតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលនោះឡើយ ដោយខ្លួនបានប្រកាសថា "ខ្លួនមិនគិតថា ការព្យាករណ៍ទុកសម្រាប់ការជំនុំជម្រះក្តីទៅថ្ងៃអនាគតទាំងនោះ អាចធ្វើទៅបានប្រកបដោយអត្ថន័យ ទាល់តែបញ្ចូលផែនការមួយនោះទេ[107]" និងមិនបានដោះស្រាយបញ្ហាពាក់ព័ន្ធទៅនឹង ថាតើការជំនុំជម្រះក្រោយៗទៀតនឹងប្រព្រឹត្តទៅយ៉ាងដូចម្តេច និងជាពិសេស ថាតើដល់ពេលណាទើបគេចាប់ផ្តើមការជំនុំជម្រះក្តីលើកទីពីរជាសក្តានុពលនៅក្នុងសំណុំរឿង ០០២ ("សំណុំរឿង ០០២/០២")[108]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានពន្យារពេល"រៀបចំកិច្ចប្រជុំរៀបចំសវនាការរហូតកៀកចុងឆ្នាំ នៅពេលបញ្ហានេះ អាចត្រូវបានពិចារណាជាថ្មីម្តងទៀត ស្របទៅតាមកាលៈទេសៈដែលកើតមាននៅពេលនោះ"[109]។

49. យោងតាមសម្អាងហេតុដែលត្រូវបានរៀបចំពេញលេញជាងមុន ក្នុងសេចក្តីសម្រេចដោយឡែកមួយ[110] អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរនេះ បានបណ្តាលឱ្យផ្អាកកិច្ចដំណើរការនីតិវិធី*តាមព្រឹត្តហេតុ* ពាក់ព័ន្ធនឹងនឹងបទចោទទាំងអស់ដែលស្ថិតនៅក្រៅវង្វង់នៃវិសាលភាពសំណុំរឿង ០០២/០១ និងថា ការផ្អាកបែបនេះពុំបានបង្ហាញឱ្យឃើញ

---

[106] សេចក្តីសម្រេចស្តីពីបំបែកកិច្ចដំណើរការនីតិវិធីដំបូងរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌទី ៥០។

[107] សេចក្តីសម្រេចស្តីពីបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ កថាខណ្ឌទី ១៥៣។

[108] សេចក្តីសម្រេចស្តីពីបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ កថាខណ្ឌទី ១៥៤-១៥៥។

[109] សេចក្តីសម្រេចស្តីពីបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ កថាខណ្ឌទី ១៥៥។

[110] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ប្រឆាំងនឹងសេចក្តីសម្រេចស្តីពីបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង–សម្អាងហេតុសង្ខេប ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E284/4/7 ("សេចក្តីសម្រេចស្តីពីបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល")។ សម្អាងហេតុពិស្តារសម្រាប់សេចក្តីសម្រេចនេះ នឹងត្រូវចេញឱ្យបាននាប់តាមដែលអាចធ្វើទៅបាន។

ច្បាស់លាស់អំពីការសន្យាថានឹងចាប់ផ្តើមកិច្ចដំណើរការនីតិវិធីឡើងវិញ ដើម្បីអាចឈានទៅរកការចេញសាលក្រមលើអង្គសេចក្តីបាននោះឡើយ។ តាមទស្សនទានរបស់អង្គជំនុំជម្រះតុលាការកំពូល វត្តមាននៃស្ថានភាពបែបនេះ តម្រូវឱ្យបន្តឃុំខ្លួន ខៀវ សំផន ទាក់ទងទៅនឹងបទចោទទាំងនោះដែលពុំអាចធ្វើយុត្តិកម្មបាន។

50. យោងតាមយុត្តិសាស្ត្រនៃតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សភាពស្មុគស្មាញនៃសំណុំរឿងគឺជាកត្តាមួយក្នុងចំណោមកត្តាជាច្រើនដែលស្ថាប័នមានសមត្ថកិច្ច អាចយកមកពិចារណាជាសម្អាងហេតុ ក្នុងការបន្តឃុំខ្លួនជនជាប់ចោទ[111]។ ទោះជាយ៉ាងនេះក្តី កត្តាទាំងនេះអាចត្រូវបានបន្តធ្វើជាយុត្តិកម្មបានតែក្នុងករណីនៃការបន្តដកហូតសេរីភាព នៅពេលដែលស្ថាប័នមានសមត្ថកិច្ច បានបង្ហាញឱ្យឃើញនូវ"ការយកចិត្តទុកដាក់ពិសេស"ក្នុងការរៀបចំកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ[112]។ មានកត្តាមួយចំនួនទៀតដែលគេត្រូវយកមកពិចារណា ពេលវាយតម្លៃអំពីភាពស្របច្បាប់នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿងស្មុគស្មាញ ដែលក្នុងនោះរួមមានវិធីសាស្ត្រដែលគេរៀបចំប្រព័ន្ធតុលាការ[113] និង ថាតើអាជ្ញាធរមូលដ្ឋានបានចាត់ចែងធនធានបន្ថែម ឬ បង្កើតអង្គភាពពិសេសមួយឬទេ ពាក់ព័ន្ធនឹងបញ្ហានេះ[114]។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ពិចារណា

---

[111] *សូមមើល ក្នុងចំណោមអត្ថបទសម្អាងផ្លូវច្បាប់ជាច្រើនផ្សេងទៀត* តុលាការសិទ្ធិមនុស្សអឺរ៉ុប សាលក្រមក្នុង*រឿងក្តី Kudla* ទល់នឹងប្រទេស ប៉ូឡូញ, សាលក្រមចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០០ ពាក្យសុំលេខ 30210/96, សេចក្តីសម្រេចស្តីពីបំបែកកថាខណ្ឌទី ១២៤ ("តុលាការនឹងវាយតម្លៃអំពីភាពសមហេតុសមផលនៃថេរៈវេលានៃកិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងកាលៈទេសៈពិសេសនៃសំណុំរឿង និង ពិចារណាលើលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងយុត្តិសាស្ត្ររបស់ខ្លួន <u>ជាពិសេសភាពស្មុគស្មាញនៃសំណុំរឿង</u> និង ការប្រព្រឹត្តរបស់អ្នកដាក់ពាក្យសុំ និង អាជ្ញាធរដែលពាក់ព័ន្ធ") (សេចក្តីបញ្ជាក់បន្ថែម)។

[112] *សូមមើលខាងលើ* ជើងទំព័រ ១០០។

[113] *សូមមើល រឿងក្តីនៅតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស រឿងក្តី Parizov ទល់នឹង*អតីតសាធារណរដ្ឋយូហ្គោស្លាវនៃប្រទេសម៉ាសេដូនី សាលក្រមចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ ពាក្យសុំលេខ 14258/03, កថាខណ្ឌទី ៥៩ ("រដ្ឋដែលចុះកិច្ចសន្យាមានភារកិច្ចរៀបចំប្រព័ន្ធច្បាប់របស់ខ្លួន ដើម្បីធ្វើយ៉ាងណាឱ្យតុលាការរបស់ខ្លួនអាចធានាសិទ្ធិរបស់ជនគ្រប់រូប ក្នុងការទទួលបានសេចក្តីសម្រេចស្ថាពរមួយ ពាក់ព័ន្ធនឹងវិវាទ [...] ក្នុងរយៈពេលសមស្របមួយ")។ *សូមមើលផងដែរ រឿងក្តី Kostovska v.* អតីត សាធារណរដ្ឋយូហ្គោស្លាវនៃប្រទេសម៉ាសេដូនី, សាលក្រមចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦ ពាក្យសុំលេខ 44353/02, កថាខណ្ឌទី ៤១។

[114] *សូមមើលរឿងក្តី* Monica Macovei, *សិទ្ធិទទួលបានសេរីភាព និង សន្តិសុខរបស់សាម៉ីខ្លួន។ មគ្គទេសក៍ទៅរកការអនុវត្តមាត្រា ៥ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស* (អគ្គនាយកសិទ្ធិមនុស្ស, ក្រុមប្រឹក្សាអឺរ៉ុប៖ ឆ្នាំ ២០០២) កថាខណ្ឌទី ៣៥-៣៦ ("ក្នុងសំណុំរឿងស្មុគស្មាញ [...] អាចជាការសំខាន់ជាពិសេសមួយដែលគេត្រូវបង្កើតអង្គភាពពិសេសមួយ ដើម្បីដោះស្រាយករណីចំពោះមុខ ឬគេត្រូវផ្តល់ធនធានបន្ថែមទៅលើធនធានដែលមានស្រាប់ ដើម្បីដោះស្រាយសំណុំរឿងដែលមានលក្ខណៈវិសាមញ្ញបែបនេះ។ ប៉ុន្តែ សំខាន់ជាងគេ គេត្រូវតែបង្ហាញឱ្យឃើញថា ថេរវេលារួមនៃកិច្ចដំណើរការនីតិវិធីត្រូវតែស្ថិតនៅក្រោម

ឃើញបន្ថែមទៀតថា ទំហំការងារដែលច្រើនសម្បើម មិនអាចយកមកធ្វើជាយុត្តិកម្ម ដើម្បីអូសបន្លាយកិច្ចដំណើរការនីតិវិធីនោះទេ[115]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវតែណែនាំវិធានការមួយចំនួន ដើម្បីធានាឲ្យបាននូវការបំពេញកិច្ចប្រកបដោយការយកចិត្តទុកដាក់ខ្ពស់សម្រាប់សំណុំរឿង ០០២ ដែលនៅសេសសល់។

51. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបានចេញបង្គាប់ថា "សវនាការដេញដោលភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ ត្រូវចាប់ផ្តើមភ្លាមៗតាមដែលអាចធ្វើទៅបាន បន្ទាប់ពីការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ និងថា សំណុំរឿង ០០២/០២ នឹងត្រូវដាក់បញ្ចូលយ៉ាងហោចបំផុតក៏ត្រឹមបទចោទពាក់ព័ន្ធនឹងមន្ទីរស-២១ ការដ្ឋានធ្វើការ សហករណ៍ និង បទឧក្រិដ្ឋប្រល័យពូជសាសន៍"ដែរ[116]។ អង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ផងដែរថា ដើម្បីសម្រេចឲ្យបាននូវសេចក្តីបង្គាប់នេះ ឥឡូវអង្គជំនុំជម្រះតុលាការកំពូលចេញអាជ្ញាបញ្ញា ឲ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរដែលមានទាំងចៅក្រមជាតិ និង អន្តរជាតិនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើសវនាការ និងសម្រេច

---

ការត្រួតពិនិត្យមួយ និង គេត្រូវស្វះស្វែងរកឲ្យអស់លទ្ធភាពដែលអាចមាន ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធទាំងនេះ")។ សូមមើលផងដែរករណីតុលាការសិទ្ធិមនុស្សអឺរ៉ុប *រឿងក្តី W. ទល់នឹងប្រទេសស្វីស* សាលក្រមចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៣ ពាក្យសុំលេខ 14379/88, កថាខណ្ឌទី ៤១-៤២ ("រដ្ឋាភិបាលត្រូវមានចំណែកក្នុងបញ្ជាក់ឲ្យបានច្បាស់ថាសំណុំរឿងនេះគឺពិតជាសំណុំរឿងដ៏លំបាកបំផុត ពាក់ព័ន្ធនឹងបទល្មើសសេដ្ឋកិច្ច ដែលមិនធ្លាប់មានពីមុនមកនៅ Canton of Berne។ សំណុំរឿងនេះមានលក្ខណៈធំលើសសំណុំរឿងទាំងអស់ផ្សេងទៀត ទាំងអង្គហេតុ និងទាំងភាពស្មុគស្មាញរបស់វា [...] <u>អាជ្ញាធរមិនបានធ្វេសប្រហែលក្នុងការបញ្ចប់សំណុំរឿង និងថែមទាំងបានបង្កើតឲ្យអង្គភាពមួយ ដែលមានសមាសភាពចៅក្រមស៊ើបអង្កេតពីររូប ដែលពួកគាត់ផ្ទាល់បានទទួលបានជំនួយពីអ្នកដែលត្រូវចាត់តាំងឲ្យធ្វើការផ្តាច់មុខតែនៅខាងអង្គភាពនោះថែមទៀតផង</u> [...] [តុលាការ] រកឃើញថា អ្នកស៊ើបអង្កេតពុំបានខកខានក្នុងការបំពេញកិច្ចស៊ើបសួររបស់ខ្លួនប្រកបដោយភាពរួសរាន់ដែលចាំបាច់ និងពុំមានការពន្យារពេលណាមួយដែលបណ្តាល មកពីកង្វះបុគ្គលិក ឬឧបករណ៍នោះឡើយ។ ជាលទ្ធផល គេឃើញថារយៈពេលនៃការឃុំខ្លួននោះ គឺត្រូវបានចាត់ទុកថាមានសារសំខាន់ ដោយសារតែភាពស្មុគស្មាញដែលមិនធ្លាប់មាននៃសំណុំរឿង និងការប្រព្រឹត្តរបស់អ្នកដាក់ពាក្យសុំ"(សេចក្តីបញ្ជាក់បន្ថែម)។

[115] *សូមមើល រឿងក្តីនៅតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស រឿងក្តី* Markoski *ទល់នឹង* អតីតសាធារណរដ្ឋយូហ្គោស្លាវនៃប្រទេសម៉ាសេដូនី, សាលក្រមចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ពាក្យសុំលេខ 22928/03, កថាខណ្ឌទី ៣៩ ("ទំហំសំណុំរឿងដែលធំសម្បើម គឺមិនអាចយកមកធ្វើជាយុត្តិកម្មក្នុងការបន្តកិច្ចដំណើរការនីតិវិធីវែងឆ្ងាយហេតុពេកបាននោះទេ")។ *រឿងក្តី Dumanovski ទល់នឹង* អតីតសាធារណរដ្ឋយូហ្គោស្លាវនៃប្រទេសម៉ាសេដូនី សាលក្រមចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៥ ពាក្យសុំលេខ 13898/02, កថាខណ្ឌទី ៤៥ ("ដោយសារតែតុលាការបានអនុវត្តជាប្រចាំតាមយុត្តិសាស្ត្រ [...] <u>ទំហំកិច្ចការក្នុងតុលាការជាតិ មិនអាចចាត់ទុកថាជាកត្តាមួយដែលយកមកធ្វើជាលេស ក្នុងការពន្យាររយៈពេលនៃកិច្ចដំណើរការនីតិវិធីបាននោះទេ</u>" (សេចក្តីបញ្ជាក់បន្ថែម)។

[116] សេចក្តីសម្រេចស្តីពីបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌទី ១៣។

សេចក្តីក្នុងសំណុំរឿង ០០២/០២ នេះ និងបានបង្គាប់ឲ្យការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ប្រញាប់រិះរកវិធានការបង្កើតស្ថាប័នមួយនេះជាបន្ទាន់[117]។ ដូច្នេះ បញ្ហានៃការឃុំខ្លួន ខៀវ សំផន ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ និងការជំនុំជម្រះក្តីជាបន្តបន្ទាប់ទៀតប្រសិនបើមាន នឹងតម្រូវឲ្យមានយុត្តិកម្ម និងការត្រួតពិនិត្យថ្មី និងដាច់ដោយឡែកមួយ ដោយតុលាការជំនុំជម្រះលើអង្គហេតុដែលត្រូវបានចាត់តាំងជាដំបូង។

52. ហេតុដូច្នេះ ក្នុងដំណាក់កាលនៃការដាក់សំណើសុំ និងបណ្តឹងសាទុក្ខ ក្រុមមេធាវីការពារក្តីបានលើកឡើងត្រឹមត្រូវចំពោះចំណុចស្តីពីការខ្វះការព្យាករទុក និងការខ្វះភាពប្រាកដប្រជារបស់តុលាការ ពាក់ព័ន្ធនឹងសំណុំរឿង ០០២ ទាំងមូល។ ទោះជាយ៉ាងនេះក្តី ចាប់ពីពេលដាក់ពាក្យសុំ និងបណ្តឹងទាំងនេះរួចមក សំណុំរឿង ០០២ ត្រូវបានបំបែកជាថ្មីម្តងទៀត ហើយសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានអនុវត្តរួចហើយទៅលើប្តឹងសាទុក្ខ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការព្យាករទុក និង ភាពប្រាកដប្រជានៃការបញ្ចប់កិច្ចដំណើរការនីតិវិធី និង សាលក្រមក្នុងសំណុំរឿង ០០២/០១ បានបង្ហាញឡើងក្នុងពេលបច្ចុប្បន្ន ហើយទឡ្ហីករណ៍ទាំងឡាយរបស់ក្រុមមេធាវីការពារក្តីដែលមានលក្ខណៈផ្ទុយ ត្រូវចាត់ទុកជាឥតបានការ។

53. អាស្រ័យដូចបានរៀបរាប់ក្នុងសម្អាងហេតុខាងលើ ក្រុមមេធាវីការពារក្តី ពុំបានបញ្ជាក់ឲ្យបានច្បាស់ថា តើការឃុំខ្លួនបណ្តោះអាសន្នលើ ខៀវ សំផន មានលក្ខណៈមិនសមាមាត្រ ឬលើសការកំណត់ដែរ ឬយ៉ាងណា នោះឡើយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធរាល់ការចោទប្រកាន់ទាំងអស់នេះ។

## គ. ការចោទប្រកាន់ថា មានកំហុសឆ្គងក្នុងការពិចារណាអំពីការប្រែប្រួលកាលៈទេសៈ

54. ក្នុងការបដិសេធសំណើសុំដោះលែងឲ្យនៅក្រៅឃុំជាបន្ទាន់ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងការបង្គាប់ឲ្យបន្តឃុំខ្លួន ខៀវ សំផន ជាបណ្តោះអាសន្នតទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សម្អាងហេតុបន្ថែមទៀតថា៖

> វិធាន ៨២(៤) នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យជនជាប់ចោទដាក់ពាក្យសុំដោះលែងជាថ្មីម្តងទៀត នៅពេលណាដែលស្ថានភាពរបស់ខ្លួនមានការប្រែប្រួល ចាប់តាំងពីពេលដែលពាក្យសុំមុន ត្រូវបានបដិសេធ។ អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបដិសេធដោះលែង ខៀវ សំផន ក្នុងខែ កុម្ភៈ

[117] សេចក្តីសម្រេចស្តីពីបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌទី ១១។ *សូមមើលផងដែរ* ដីកាពាក់ព័ន្ធនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារលេខ E284/4/7/1។

ឆ្នាំ ២០១១។ អង្គជំនុំជម្រះមិនបានរកឃើញការប្រែប្រួលណាមួយនៃស្ថានភាពរបស់គាត់ចាប់តាំងពីកាលបរិច្ឆេទនោះ ដែលនឹងអនុញ្ញាតឲ្យអង្គជំនុំជម្រះសម្រេចតាមពាក្យសុំក្នុងពេលនេះរបស់គាត់បាននោះឡើយ[118]។

55. ក្រុមមេធាវីការពារក្តី អះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសលើអង្គច្បាប់ ក្នុងការយោងទៅលើវិធាន ៨២(៤) នៃវិធានផ្ទៃក្នុង និង ក្នុងការពិចារណាថាតើកាលៈទេសៈមានការប្រែប្រួលណាមួយ ដែរ ឬយ៉ាងណា ចាប់តាំងពីដាក់ពាក្យសុំដោះលែងលើកមុនរបស់ ខៀវ សំផន ទោះបីជាអង្គជំនុំជម្រះខ្លួនឯងធ្លាប់បានសម្រេចកាលពីលើកមុនថា លក្ខខណ្ឌបែបនេះមិនអាចអនុវត្តបានក្នុងពាក្យសុំជាថ្មីម្តងទៀតណាមួយដែលស្រដៀងគ្នានេះឡើយ[119]។

56. សហព្រះរាជអាជ្ញាយល់ស្របថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុស ក្នុងការពិនិត្យមើលលក្ខខណ្ឌតម្រូវក្នុងវិធាន ៨២(៤) នៃវិធានផ្ទៃក្នុងនេះ ប៉ុន្តែលើកឡើងថាក្រុមមេធាវីការពារក្តីមិនបានបង្ហាញនូវការបាត់បង់ប្រយោជន៍ណាមួយដែលកើតចេញពីការសម្រេចដូច្នេះ ដែលអាចនាំឲ្យមានមោឃភាពលើសេចក្តីសម្រេចដែលរងការជំទាស់នោះឡើយ[120]។

57. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នៅក្នុងសេចក្តីសម្រេចដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំដោះលែងជាបន្ទាន់ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា "ដោយពិចារណាទៅលើការខ្វះការជូនដំណឹងជាមុនទៅដល់ភាគី ដើម្បីឲ្យពួកគេអាចត្រៀមខ្លួនបានគ្រប់គ្រាន់ក្នុងការដាក់សារណាពាក់ព័ន្ធនឹងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងមិនតម្រូវឲ្យក្រុមមេធាវីការពារក្តីបង្ហាញអំពីការប្រែប្រួលនៃស្ថានភាព ក្នុងវិធាន ៨២(៤) នៃវិធានផ្ទៃក្នុង ប្រសិនបើក្រុមមេធាវីការពារក្តីមានបំណងដាក់ពាក្យសុំដោះលែងសាជាថ្មីម្តងទៀត នៅចំពោះមុខអង្គជំនុំជម្រះ"[121]។ ភាពសមរម្យនៃដំណោះស្រាយរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានតម្កល់ទុកនៅពេលសម្រេចលើបណ្តឹងសាទុក្ខ[122]។ ដូច្នេះ ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូង អនុវត្តតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងវិធាន ៨២(៤) នៃវិធានផ្ទៃក្នុង ទោះបីខ្លួនធ្លាប់បានគូសបញ្ជាក់ម្តងហើយយ៉ាងណាក្តី ក៏ការណ៍នេះមិនមែនជាបញ្ហាចោទនោះឡើយ។ ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូង មិនបានរកឃើញថាមានការប្រែប្រួលស្ថានភាពណាមួយ ចាប់តាំងពីការដាក់សំណើសុំដោះលែងជាបន្ទាន់ចុងក្រោយរបស់ ខៀវ សំផន និង

[118] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌទី ២៣។

[119] បណ្តឹងសាទុក្ខ កថាខណ្ឌទី ៧៥-៧៨។

[120] ចម្លើយតប កថាខណ្ឌទី ៤២-៤៧។

[121] សេចក្តីសម្រេចដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការដោះលែងភ្លាមៗ កថាខណ្ឌទី ៤២។

[122] សេចក្តីសម្រេចដំបូងរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីការដោះលែងភ្លាមៗ កថាខណ្ឌទី ៥១។

ករណីដែលអង្គជំនុំជម្រះពុំបានធ្វើសវនាការស្តាប់ក្រុមមេធាវីការពារក្តីមុនសិន ក៏ជារឿងច្បាស់លាស់ និងជាក់ស្តែងមួយផងដែរ។ ដូច្នេះ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរកឃើញថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសលើអង្គច្បាប់។

58. ទោះជាយ៉ាងនេះក្តី ផ្ទុយពីអ្វីដែលមានចែងក្នុងវិធាន ១០៥(២) នៃវិធានផ្ទៃក្នុង ក្រុមមេធាវីការពារក្តីពុំបានបញ្ជាក់ថាកំហុសឆ្គងរបស់អង្គជំនុំជម្រះសាលាដំបូងនេះ នាំឲ្យមានមោឃភាពលើសេចក្តីសម្រេចដែលរងការជំទាស់នោះឡើយ[123]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូង មិនបានពិចារណាវិធាន ៨២(៤) នៃវិធានផ្ទៃក្នុង ក្នុងការដោះស្រាយបញ្ហាខាងលើយ៉ាងណាក្តី ក៏អង្គជំនុំជម្រះតុលាការកំពូលរកឃើញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការបន្តឃុំខ្លួន ខៀវ សំផន នៅតែមានលក្ខណៈចាំបាច់ដដែលនោះ គឺពុំមានអ្វីដែលមិនសមហេតុសមផល ក្នុងការទទួលបានការធ្វើអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូលដូច្នេះនោះឡើយ។ ដូច្នេះ ទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តីពាក់ព័ន្ធនឹងបញ្ហានេះត្រូវបានបដិសេធ។

---

[123] វិធាន ១០៥(២) នៃវិធានផ្ទៃក្នុងចែងថា "ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបើកផ្លូវសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤(៤) ត្រូវដាក់បណ្តឹងសាទុក្ខភ្លាមៗនេះ ដោយបញ្ជាក់ពីមូលដ្ឋានគាំទ្របណ្តឹងសាទុក្ខ និង ទឡ្ហីករណ៍នានា។ មូលដ្ឋាននីមួយៗនៃបណ្តឹងសាទុក្ខត្រូវៈ ក) បញ្ជាក់អំពីកំហុសអង្គច្បាប់ និង ត្រូវបង្ហាញថាកំហុសនោះបណ្តាលឲ្យមានសេចក្តីសម្រេចមានមោឃភាព ឬ ខ) បញ្ជាក់ពីកំហុសដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់ពាក្យបណ្តឹងសាទុក្ខ ឬ គ) បញ្ជាក់អំពីកំហុសអង្គហេតុ និង ត្រូវបង្ហាញថាកំហុសនេះ នាំឲ្យមានការភ័ន្តច្រឡំក្នុងការសម្រេចសេចក្តីរបស់តុលាការ"។

## V. ផ្នែកសម្រេចសេចក្តី

59. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖

**ទទួលយក** បណ្តឹងសាទុក្ខ ដោយអនុលោមតាមវិធាន ១០៤(៤)(ខ) នៃវិធានផ្ទៃក្នុង និង

**បដិសេធ** បណ្តឹងសាទុក្ខនេះចោលទាំងមូល។

ភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**